# AEON CARD

## បញ្ញត្តិ និងលក្ខខណ្ឌអ៊ីអនកាត

## CREDIT CARD TERMS & CONDITIONS




ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
ÆON SPECIALIZED BANK (CAMBODIA) PLC.

# តារាងមាតិកា


| | ទំព័រ |
|---|---|
| សារៈសំខាន់ | ១ |
| លក្ខខណ្ឌទូទៅ | ១ |
| ប្រការ ១ និយមន័យ | ២ |
| ប្រការ ២ កាតព្វកិច្ចបង់ប្រាក់របស់ម្ចាស់កាត | ៤ |
| ប្រការ ៣ កាតបន្ថែម | ៥ |
| ប្រការ ៤ ភស្តុតាងនៃកិច្ចព្រមព្រៀង | ៦ |
| ប្រការ ៥ ការប្រើប្រាស់លេខសម្ងាត់ | ៦ |
| ប្រការ ៦ ការបង្ហាញលេខសម្ងាត់ ឬការបាត់ ចោរលួច ឬការប្រើប្រាស់ដោយគ្មានការអនុញ្ញាត្តិ | ៧ |
| ប្រការ ៧ កាតគឺជាទ្រព្យសម្បត្តិរបស់ធនាគារឯកទេស អ៊ីអន | ៨ |
| ប្រការ ៨ កាតមិនត្រូវផ្ទេរ ឬបញ្ចាំ | ៩ |
| ប្រការ ៩ កាតមិនត្រូវប្រើប្រាស់ក្នុងសកម្មភាពខុសច្បាប់ | ៩ |
| ប្រការ ១០ ប្រតិបត្តិការជាមួយពាណិជ្ជករ | ៩ |
| ប្រការ ១១ ការដកសាច់ប្រាក់ជាមុន ការប្រាក់ និង ការប្តូររូបិយបណ្ណសម្រាប់ប្រតិបត្តិការបរទេស | ១០ |
| ប្រការ ១២ ការទិញលក់រាយដែលបានធ្វើនៅបរទេស | ១១ |
| ប្រការ ១៣ ការប្រើប្រាស់ប្រតិបត្តិការឥណទានតាមអ៊ីនធើណេត | ១១ |
| ប្រការ ១៤ សិទ្ធរបស់ធនាគារឯកទេស អ៊ីអន ក្នុងការគិតសេវា និង/ឬកម្រៃផ្សេងៗ | ១១ |
| ប្រការ ១៥ ការបែងចែកការទូទាត់ | ១២ |
| ប្រការ ១៦ ការទូទាត់អប្បបរមា និង ការប្រាក់លើការទិញលក់រាយ | ១២ |
| ប្រការ ១៧ ការពិន័យលើការបង់យឺត | ១៣ |
| ប្រការ ១៨ ភស្តុតាងនៃការជំពាក់ប្រាក់ | ១៣ |
| ប្រការ ១៩ ការប្រើប្រាស់លើសចំនួនកម្រិតឥណទានដែលបានកំណត់ | ១៤ |
| ប្រការ ២០ ការបង់ប្រាក់ | ១៤ |
| ប្រការ ២១ ករណីមានកំហុស | ១៥ |
| ប្រការ ២២ ការរួមបញ្ចូលគ្នានៃគណនីឥណទាន និងការទូទាត់សង | ១៦ |
| ប្រការ ២៣ ការបញ្ចប់ការប្រើប្រាស់កាតដោយម្ចាស់កាត | ១៧ |
| ប្រការ ២៤ ការកែប្រែផ្សេងៗ ឬការផ្លាស់ប្តូរបញ្ញត្តិ និង លក្ខខណ | ១៧ |
| ប្រការ ២៥ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការដកសម្បទាណាមួយឬការបញ្ឈប់ការប្រើប្រាស់កាត | ១៨ |
| ប្រការ ២៦ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការដកយកមកវិញនូវកម្រិតឥណទានឬបដិសេធឲ្យប្រើប្រាស់កាត | ១៨ |

ប្រការ ២៧ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការពិនិត្យ ឥណទានដែលមាន ១៩
ប្រការ ២៨ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការបង្ហាញ ព័ត៌មាន ១៩
ប្រការ ២៩ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការតែង តាំងភ្នាក់ងារ ២០
ប្រការ ៣០ ភស្តុតាងពិតប្រាកដ ២០
ប្រការ ៣១ វិវាទ ២១
ប្រការ ៣២ ការប្រឆាំងនឹងការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្មនិង ការត្រួតពិនិត្យលើការដាក់ទណ្ឌកម្ម ផ្សេងៗ ២១
ប្រការ ៣៣ ការកែតម្រូវប្រតិបត្តិការ ២៣
ប្រការ ៣៤ វិក្កយបត្របញ្ជាក់ពីការបង់ប្រាក់ ២៤
ប្រការ ៣៥ NO COOLING OFF ២៤
ប្រការ ៣៦ សោហ៊ុយ និងការចំណាយ ២៤
ប្រការ ៣៧ សំណង ២៤
ប្រការ ៣៨ ការបោះបង់សិទ្ធិ ២៤
ប្រការ ៣៩ សារៈសំខាន់នៃពេលវេលា ២៤
ប្រការ ៤០ អនុប្បទាននៃសិទ្ធិ ២៥
ប្រការ ៤១ ស្វ័យភាពនៃប្រការដែលមានចែង ២៥
ប្រការ ៤២ ច្បាប់គ្រប់គ្រង និងយុត្តាធិការ ២៥
ប្រការ ៤៣ ការអនុវត្តនៃឯកសារបន្ថែម ២៥
ប្រការ ៤៤ សេចក្តីជូនដំណឹងស្តីពីការផ្លាស់ប្តូរ ២៥
ប្រការ ៤៥ ការចាកចេញរបស់ម្ចាស់កាតពីកម្ពុជា ២៥
ប្រការ ៤៦ លក្ខណៈខាងក្រៅ និងផលប្រយោជន៍នៃការធ្វើ កាតម្តងទៀត ២៦
ប្រការ ៤៧ វិវាទរវាងភាសាអង់គ្លេស និងភាសាដទៃទៀត ២៦
ប្រការ ៤៨ ការផ្សាយនៃបញ្ញត្តិ និងលក្ខខណ្ឌនៅគេហទំព័រ របស់ធនាគារឯកទេស អ៊ីអន ២៦
ប្រការ ៤៩ ករណីប្រធានសក្តិ ២៦
ប្រការ ៥០ ការទាក់ទងតាមរយៈទូរស័ព្ទដៃ ២៧

## សារៈសំខាន់

សូមអានដោយប្រុងប្រយ័ត្នទៅលើបញ្ញត្តិ និងលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ និងប្រើប្រាស់អ៊ីអនកាតរបស់អ្នកនៅធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ប្រសិនបើអ្នកយល់ព្រមលើបញ្ញត្តិ និងលក្ខខណ្ឌដូចដែលមានចែងនេះ។ តាមរយៈការប្រើប្រាស់កាតរបស់អ្នក (ដូចដែលបានឱ្យនិយមន័យនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ) អ្នកត្រូវបានសន្មតថាបានទទួលយកបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះដូចដែលមានចែងនេះ ហើយត្រូវចងកាតព្វកិច្ចដោយបញ្ញត្តិ និងលក្ខខណ្ឌនេះ។

## លក្ខខណ្ឌទូទៅ

តាមការពិចារណារបស់ **ធនាគារឯកទេស អ៊ីអន** ( **ខេមបូឌា** ) **ភីអិលស៊ី** (ចាប់ពីពេលនេះតទៅហៅថា "**ធនាគារឯកទេស អ៊ីអន**") បានផ្តល់ជូននូវសេវាកម្មទៅម្ចាស់អ៊ីអនកាត (ដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ) ទៅតាមការស្នើសុំរបស់ម្ចាស់កាតតាមឥណទានទាំងឡាយដូចខាងក្រោម (ដោយហៅជារួមថា "**ឥណទាន**") ដែលត្រូវបានផ្តល់ឱ្យពាក់ព័ន្ធទៅនឹងការប្រើប្រាស់កាត ដែលចេញដោយ ធនាគារឯកទេស អ៊ីអន៖

ក. រាល់ការចំណាយសម្រាប់ការទិញទំនិញ និងឬ សេវាកម្ម ដែលការចំណាយត្រូវកាត់ចេញពីគណនី អ៊ីអនកាត (ដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ)

ខ. រាល់ការដកយកសាច់ប្រាក់ជាមុន ដែលត្រូវកាត់ចេញពីគណនី អ៊ីអនកាត

គ. រាល់ឥណទានដទៃទៀត ដែលអាចផ្តល់ដោយ ធនាគារឯកទេស អ៊ីអន នៅពេលណាមួយអាស្រ័យលើការរៀបចំជាមួយ ធនាគារឯកទេស អ៊ីអន។

តទៅម្ចាស់កាតយល់ព្រមលើបញ្ញត្តិ និងលក្ខខណ្ឌទាំងឡាយដូចខាងក្រោម៖

## ប្រការ ១ និយមន័យ

១.១ នៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនៃខ្លឹមសារឆ្លើយតបទៅនឹងការបង្ហាញខាងក្រោមនេះ ត្រូវមានអត្ថន័យដូចខាងក្រោមលើកលែងមានចែងផ្ទុយពីនេះ៖

ក. "**ធនាគារឯកទេស អ៊ីអន**" មានន័យថា ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ស្ថិតនៅជាន់ទី៦ (អេស ៦០៣) អគារ Diamond Twin Tower ផ្លូវសុភមង្គល កែងផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ហើយរាប់បញ្ចូលទាំងសន្តតិជនតាមការស្នងតំណែង និងតាមការផ្ទេរអនុប្បទានរបស់ធនាគារ។

ខ. "**ឥណពន្ធស្វ័យប្រវត្តិអ៊ីអន**" មានន័យថា ជាសេវាទូទាត់ផ្តល់ដោយធនាគារឯកទេស អ៊ីអន ហើយដែលម្ចាស់កាតផ្តល់សិទ្ធិឱ្យធនាគារឯកទេស អ៊ីអន ដើម្បីទូទាត់វិក្កយបត្រ ដែលចេញដោយអ្នកផ្គត់ផ្គង់សេវាកម្មទៅឱ្យ ធនាគារឯកទេស អ៊ីអន ដោយកាត់ចេញពីគណនីអ៊ីអនកាតរបស់ម្ចាស់កាត។

គ. "**ម៉ាស៊ីន ATM**" មានន័យថាជាម៉ាស៊ីនបង្ហាញសាច់ប្រាក់ដោយស្វ័យប្រវត្តិ រួមទាំងម៉ាស៊ីនដាក់ប្រាក់។

ឃ. "**វិក្កយបត្រ**" មានន័យថាវិក្កយបត្រក្នុងអំឡុងពេលណាមួយ ដែលចេញដោយអ្នកផ្គត់ផ្គង់សេវាកម្មទៅឱ្យបុគ្គល (រូបវន្តបុគ្គល ឬនីតិបុគ្គលដទៃទៀត) ដែលទទួលយកលក្ខខណ្ឌនៃការប្រើប្រាស់ ឬសេវាកម្មពីអ្នកផ្គត់ផ្គង់សេវាកម្ម។

ង. "**អ៊ីអនកាត**" មានន័យថា ប័ណ្ណឥណទានដើម ឬប័ណ្ណឥណទានបន្ថែម។

ច. "**គណនីអ៊ីអនកាត**" មានន័យថាជាគណនីឥណទានរបស់ម្ចាស់កាតក្នុងករណីអាចណាមួយ ដែលធនាគារឯកទេស អ៊ីអន ត្រូវគិតថ្លៃទាំងអស់នូវអ្វីដែលអាចកើតមានពីការប្រើប្រាស់ឥណទានរបស់ម្ចាស់កាត រួមទាំងការប្រាក់ សោហ៊ុយ និងការគិតប្រាក់ទាំងអស់ ដែលត្រូវបង់ស្របតាមកិច្ចព្រមព្រៀងនេះ។

ឆ. "**ម្ចាស់កាត**" មានន័យថាម្ចាស់កាតដើម ឬម្ចាស់កាតបន្ថែម។

ជ. "**កាតដែលចេញរួមគ្នា**" មានន័យថាជាកាតដែលចេញដោយធនាគារឯកទេស អ៊ីអន ឬរួមគ្នាដោយធនាគារឯកទេសអ៊ីអន និងបុគ្គលផ្សេងទៀត ឬសាជីវកម្មផ្សេងទៀត ដែលអាចជាករណី ដែលធនាគារឯកទេសអ៊ីអន ចុះកិច្ចព្រមព្រៀងរួម គ្រោងការណ៍រួម ឬកម្មវិធីរួម សម្រាប់កាតដែលចេញរួមគ្នានេះ។

ឈ. "**កម្រិតឥណទាន**" មានន័យថាកម្រិតឥណទានផ្តល់ដោយ ធនាគារឯកទេស អ៊ីអន ទៅម្ចាស់កាត ហើយកម្រិតឥណទាន ត្រូវស្របតាមប្រភេទណាមួយនៃកាត ដែលចេញដោយ ធនាគារ ឯកទេស អ៊ីអន ហើយអាចកែប្រែដោយ ធនាគារឯកទេស អ៊ីអន តាមឆន្ទានុសិទ្ធិរបស់ខ្លួននាពេលណាមួយ។ ប្រសិនបើកាតបន្ថែម ត្រូវបានចេញ ម្ចាស់កាតដើម និងម្ចាស់កាតបន្ថែម អាចត្រូវមាន កម្រិតឥណទានដូចគ្នា ឬកម្រិតឥណទានក្នុងសមាមាត្រណាមួយ ដែល ធនាគារឯកទេស អ៊ីអន អាចកំណត់តាមឆន្ទានុសិទ្ធិផ្តាច់ មុខនៅពេលណាមួយ។

ញ. "**សមតុល្យបច្ចុប្បន្ន**" មានន័យថាជាចំនួនទឹកប្រាក់ ដែលបង្ហាញ នៅក្នុងរបាយការណ៍ ឬសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ណាមួយ ដែលបានទំនាក់ទំនងទៅម្ចាស់កាតដោយ ធនាគារ ឯកទេស អ៊ីអន។

ដ. "**ការពិន័យលើការបង់យឺត**" មានន័យថាការគិតប្រាក់លើការបង់ យឺតដូចមានចែងនៅប្រការ ១៧ ខាងក្រោម។

ឋ. "**ពាណិជ្ជករ**" មានន័យថាជាពាណិជ្ជករណាម្នាក់ ដែលផ្គត់ផ្គង់ ទំនិញ និង/ឬ សេវាកម្ម។

ឌ. "**កាលបរិច្ឆេទដែលត្រូវបង់ប្រាក់**" មានន័យថាជាកាលបរិច្ឆេទដែល ម្ចាស់កាតត្រូវទូទាត់នូវទឹកប្រាក់អប្បបរមាជាក់លាក់ ឬសមតុល្យ បច្ចុប្បន្ន និងដូចដែលមានបញ្ជាក់នៅក្នុងរបាយការណ៍។

ឍ. "**កាតដើម**" មានន័យថាអ៊ីអនកាត ដែលចេញដោយ ធនាគារ ឯកទេស អ៊ីអន និងត្រូវរាប់បញ្ចូលទាំងកាត ដែលចេញរួមគ្នាជា លក្ខណៈសម្ព័ន្ធភាព ឬលក្ខណៈរួមជាមួយតតិយជន និង/ឬ ក្រោមឈ្មោះនៃផលិតផលណាមួយ ឬឈ្មោះដែលជ្រើសរើស ឬ ការយោង។

ណ. "**ម្ចាស់កាតដើម**" ជាបុគ្គលដែលមានឈ្មោះនៅលើកាត ហើយ រួមបញ្ចូលទាំងអ្នកតំណាងផ្ទាល់ខ្លួនរបស់គាត់។

ត. "**លេខសម្ងាត់**" មានន័យថាលេខសម្គាល់អត្តសញ្ញាណផ្ទាល់ខ្លួន របស់ម្ចាស់កាតជាលេខកូដ ដែលអាចប្រើប្រាស់សេវាកម្មបាន តាមរយៈម៉ាស៊ីន ATM របស់ធនាគារឯកទេស អ៊ីអន ឬស្ថាប័ន ដែល ធនាគារឯកទេសអ៊ីអន មានការរៀបចំសម្រាប់ការប្រើប្រាស់ ម៉ាស៊ីន ATM នៃធនាគារណាមួយ ឬស្ថាប័នហិរញ្ញវត្ថុណាមួយ ខាងលើ ដែលភ្ជាប់ប្រើប្រាស់កាតបាន។

ថ. "**ពិន្ទុសន្សំ**" មានន័យថាពិន្ទុ ដែលត្រូវបានគេផ្តល់ឱ្យម្ចាស់កាត ស្របតាមកម្មវិធីសប្បាយៗសន្សំពិន្ទុធនាគារឯកទេស អ៊ីអន។

ទ. "**អ្នកផ្គត់ផ្គង់សេវាកម្ម**" មានន័យថាជាសាជីវកម្ម ឬភាគីដែលចុះកិច្ចសន្យាជាមួយ ធនាគារឯកទេស អ៊ីអន ដើម្បីអនុញ្ញាតឱ្យមានការទូទាត់វិក្កយបត្រដោយអ្នកប្រើប្រាស់ ដែលជាម្ចាស់កាតធ្វើឡើងតាមរយៈឥណពន្ធស្វ័យប្រវត្តិអ៊ីអន ឬវិធីទូទាត់ណាមួយដែលបានកំណត់ដោយធនាគារឯកទេស អ៊ីអន។

ធ. "**ការបង់ប្រាក់អប្បបរមាជាក់លាក់**" មានន័យថាជាការទូទាត់ដែលតម្រូវឱ្យបង់ដោយម្ចាស់កាតស្របតាមប្រការ ១៦ នៃកិច្ចព្រមព្រៀងនេះ។

ន. "**របាយការណ៍**" មានន័យថាជារបាយការណ៍ប្រចាំខែចេញដោយធនាគារឯកទេស អ៊ីអន ទៅឱ្យម្ចាស់កាតដោយបង្ហាញពីចំនួនផ្សេងៗ ដែលត្រូវគិតប្រាក់ និងកាលបរិច្ឆេទដែលត្រូវបង់ប្រាក់។

ប. "**អ្នកប្រើប្រាស់**" មានន័យថាបុគ្គល (រូបវន្តបុគ្គល ឬនីតិបុគ្គលផ្សេងទៀត) ដែលចុះឈ្មោះប្រើប្រាស់ទំនិញ ឬសេវាកម្មដែលផ្តល់ដោយអ្នកផ្គត់ផ្គង់សេវាកម្ម និង/ឬអ្នកតំណាងស្របច្បាប់របស់ខ្លួនដទៃទៀត។

ផ. "**កាតបន្ថែម**" មានន័យថាកាតបន្ថែម ដែលចេញដោយ ធនាគារឯកទេស អ៊ីអន ទៅឱ្យម្ចាស់កាតបន្ថែម ដែលត្រូវបានតែងតាំងដោយម្ចាស់កាត និងអនុញ្ញាតដោយ ធនាគារឯកទេស អ៊ីអន។

ព. "**ម្ចាស់កាតបន្ថែម**" មានន័យថាជាបុគ្គល ដែលតែងតាំងដោយម្ចាស់កាត ដើម្បីក្លាយទៅជាម្ចាស់កាតបន្ថែម ហើយជាអ្នកដែលទទួលបានកាតបន្ថែម ដែលចេញដោយ ធនាគារឯកទេស អ៊ីអន។

ភ. "**ម៉ាកប័ណ្ណឥណទានអន្តរជាតិ**"(International Credit Card Brand) មានន័យថាជាក្រុមហ៊ុនដែលចេញ VISA, MasterCard, JCB, China UnionPay និងអ្នកដែលផ្តល់បណ្តាញបង្កើតប្រតិបត្តិការប័ណ្ណឥណទានរវាងធនាគាររបស់ពាណិជ្ជករ និងអ្នកចេញប័ណ្ណឥណទាន។

ម. "**ប្រតិបត្តិការ**" មានន័យថាការប្រើប្រាស់ប័ណ្ណដើម្បីទូទាត់ទៅលើទំនិញ និង/ឬសេវាកម្ម ឬការដកសាច់ប្រាក់ពីម៉ាស៊ីន ATM ពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។

**១.២** ចំណងជើងនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានដាក់បញ្ចូលជាឯកសារយោងតែប៉ុណ្ណោះ ហើយវាមិនត្រូវបានលើកយកមកអធិប្បាយនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះទេ។

## ប្រការ ២ កាតព្វកិច្ចបង់ប្រាក់របស់ម្ចាស់កាត

ម្ចាស់កាតទទួលខុសត្រូវក្នុងការទូទាត់ប្រាក់លើគ្រប់ប្រតិបត្តិការ និងការប្រាក់សោហ៊ុយ និងការចំណាយទាំងអស់ធ្វើឡើងក្រោមគណនីអ៊ីអនកាត សម្រាប់ការ

ប្រើប្រាស់កាតរួមបញ្ចូល តែមិនកំណត់លើសោហ៊ុយ ដែលមិនអាចដកវិញបាន កាតព្វកិច្ចពន្ធ ដែលចែងដោយច្បាប់ រហូតមានការបង់ប្រាក់គ្រប់ចំនួនទៅឱ្យ ធនាគារឯកទេស អ៊ីអន ត្រូវបានធ្វើឡើងដោយគ្មានការស្នើសុំវិក្កយបត្រ ហត្ថលេខា ឬឯកសារយោងផ្សេងទៀត។ កាតព្វកិច្ចបង់ប្រាក់របស់ម្ចាស់កាតនឹងបន្តសុពលភាពក្នុងករណីមានការធ្វើកាតបន្ត ឬកាតជំនួសដោយ ធនាគារឯកទេស អ៊ីអន ហើយក៏ដូចក្នុងករណីបញ្ចប់ដោយហេតុផលណាមួយ។ ដោយគ្មានការជូនដំណឹងជាមុនទៅម្ចាស់កាត ធនាគារឯកទេស អ៊ីអន មានសិទ្ធិពេញលេញក្នុងការៈ

ក. យល់ព្រម ឬបដិសេធការចេញកាតទៅឱ្យម្ចាស់កាត ទោះបីជាម្ចាស់កាតបានបំពេញគ្រប់លក្ខខណ្ឌរបស់ ធនាគារឯកទេស អ៊ីអន ក៏ដោយ។
ខ. បដិសេធ ឬយល់ព្រមលើប្រតិបត្តិការទាំងឡាយ ទោះបីជាប្រតិបត្តិការស្ថិតក្រោមកម្រិតឥណទានដែលមាន។
គ. បញ្ចប់ការប្រើប្រាស់កាតពីម្ចាស់កាត នៅពេលណាមួយ។
ឃ. បង្កើន ឬបន្ថយកម្រិតឥណទាន។
ង. បដិសេធចេញជាថ្មី បន្តជាថ្មី ឬជំនួស និង
ច. កែប្រែ កែតម្រូវកម្រិត ឬលុបចោលសេវាកម្មលក្ខខណ្ឌខាងក្រៅរបស់កាត និងគណនីអ៊ីអនកាតរបស់ម្ចាស់កាត។

ធនាគារឯកទេស អ៊ីអន មិនទទួលខុសត្រូវលើការចំណាយ ឬការខូចខាតណាមួយ ដែលទាមទារដោយម្ចាស់កាត ក្នុងករណី ធនាគារឯកទេស អ៊ីអន មិនអនុញ្ញាតលើប្រតិបត្តិការណាមួយពីគណនីអ៊ីអនកាតរបស់ម្ចាស់កាត និង/ឬ ប្រសិនបើពាណិជ្ជករមិនទទួលយកកាត ទោះបីជាប្រតិបត្តិការនោះស្ថិតក្រោមកម្រិតឥណទានដែលមាន។

ធនាគារឯកទេស អ៊ីអន អាចកម្រិតបរិមាណប្រចាំថ្ងៃ និង/ឬចំនួនប្រតិបត្តិការប្រចាំថ្ងៃ។

ប្រសិនបើ ធនាគារឯកទេស អ៊ីអន រកឃើញថាមានសកម្មភាពមិនប្រក្រតី ឬមន្ទិលសង្ស័យនៅក្នុងគណនីអ៊ីអនកាត ធនាគារឯកទេស អ៊ីអន អាចស្នើឱ្យម្ចាស់កាតទាក់ទងមក ធនាគារឯកទេស អ៊ីអន និង/ឬព្យួរបណ្ដោះអាសន្ននូវសិទ្ធិខ្លះ ឬទាំងអស់ក្នុងការប្រើប្រាស់កាតរហូតដល់ ធនាគារឯកទេស អ៊ីអន ត្រួតពិនិត្យសកម្មភាពទាំងនោះ។

តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារឯកទេស អ៊ីអន អាចអនុញ្ញាតប្រតិបត្តិការលើតម្លៃសរុបលើសពីកម្រិតឥណទាន។ ហានិភ័យណាមួយ ឬទាំងអស់ពាក់ព័ន្ធនឹងប្រតិបត្តិការជាបន្ទុករបស់ម្ចាស់កាត។

## ប្រការ ៣ កាតបន្ថែម

៣.១ តាមឆន្ទានុសិទ្ធិផ្តាច់មុខ និងតាមការស្នើសុំរបស់ម្ចាស់កាត ធនាគារឯកទេស អ៊ីអន អាចចេញកាតបន្ថែមទៅម្ចាស់កាតបន្ថែម។ រាល់បញ្ញត្តិ

និងលក្ខខណ្ឌដូចដែលមានចែងក្នុងប្រការនេះ ត្រូវអនុវត្តលើករណីផ្សេងទៀតរបស់ម្ចាស់កាតបន្ថែម ហើយម្ចាស់កាតបន្ថែមអាចអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌផ្សេង ដែលធនាគារឯកទេស អ៊ីអន សន្មតថាជាការចាំបាច់។

៣.២ ម្ចាស់កាតដើមត្រូវទទួលខុសត្រូវចំពោះ ធនាគារឯកទេស អ៊ីអន នូវទឹកប្រាក់សរុបទាំងអស់ ដែលដល់កំណត់សង និងនៅជំពាក់ ធនាគារឯកទេស អ៊ីអន ដែលកើតឡើងពីការប្រើប្រាស់ទាំងកាតដើម និងកាតបន្ថែម ប៉ុន្តែម្ចាស់កាតបន្ថែមម្នាក់ៗត្រូវទទួលខុសត្រូវចំពោះ ធនាគារឯកទេស អ៊ីអន តែលើទឹកប្រាក់សរុបទាំងអស់ ដែលដល់កំណត់សង និងនៅជំពាក់ ធនាគារឯកទេស អ៊ីអន ដែលកើតឡើងពីការប្រើប្រាស់កាតបន្ថែមរបស់ខ្លួនតែប៉ុណ្ណោះ។

៣.៣ ធនាគារឯកទេស អ៊ីអន រក្សាសិទ្ធិក្នុងការបង្ហាញព័ត៌មានទាក់ទង នឹងម្ចាស់កាតបន្ថែមទៅឱ្យម្ចាស់កាតដើម រួមបញ្ចូលតែមិនកំណត់ទៅលើស្ថិតិនៃប្រតិបត្តិការ និងស្ថិតិនៃចំនួនទឹកប្រាក់ ដែលនៅជំពាក់របស់កាតបន្ថែម។

៣.៤ សុពលភាពនៃកាតបន្ថែម គឺផ្អែកលើសុពលភាពនៃកាតដើម។ តាមរយៈការបញ្ចប់ការប្រើប្រាស់កាតដើម ឬកិច្ចព្រមព្រៀងរបស់ម្ចាស់កាតដើមជាមួយ ធនាគារឯកទេស អ៊ីអន ដោយមូលហេតុអ្វីក៏ដោយ ការប្រើប្រាស់កាតបន្ថែម ដែលបានចេញរួចហើយនោះត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ។ ការបញ្ចប់ការប្រើប្រាស់កាតបន្ថែម ឬកិច្ចព្រមព្រៀងរបស់ម្ចាស់កាតបន្ថែមជាមួយ ធនាគារឯកទេស អ៊ីអន ដោយមូលហេតុអ្វីក៏ដោយមិនត្រូវបញ្ចប់ការប្រើប្រាស់នៃកាតដើម ឬកិច្ចព្រមព្រៀងរបស់ម្ចាស់កាតដើមជាមួយធនាគារឯកទេស អ៊ីអន ឡើយលើកលែងករណីមានមូលហេតុច្បាស់លាស់ក្នុងការបញ្ចប់ជាមួយនឹងម្ចាស់កាតដើម។

## ប្រការ ៤ ភស្តុតាងនៃកិច្ចព្រមព្រៀង

តាមរយៈវិក្កយបត្រនៃកាត ម្ចាស់កាតត្រូវចុះហត្ថលេខាភ្លាមៗទៅលើកាត ហើយហត្ថលេខានេះ និង/ឬការប្រើប្រាស់កាតត្រូវសន្មតថាជាការចងភ្ជាប់កាតព្វកិច្ច និងជាភស្តុតាងពិតប្រាកដនៃកិច្ចព្រមព្រៀងរបស់ម្ចាស់កាត ដែលត្រូវអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

## ប្រការ ៥ ការប្រើប្រាស់លេខសម្ងាត់

៥.១ លេខសម្ងាត់ត្រូវបានចេញ និងប្រគល់ទៅម្ចាស់កាតដើម្បីទទួលខុសត្រូវលើហានិភ័យដោយខ្លួនឯង។

៥.២ លេខសម្ងាត់គឺត្រូវរក្សាការសម្ងាត់បំផុត និងមិនត្រូវបង្ហាញទៅនរណាម្នាក់ទោះក្នុងកាលៈទេសៈណាក៏ដោយ ឬវិធីណាក៏ដោយ ទោះជាមានការស្ម័គ្រចិត្ត ឬផ្សេងពីនេះ។

៥.៣ ម្ចាស់កាតមិនត្រូវរក្សាទុកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃលេខសម្ងាត់របស់គាត់នៅកន្លែង ឬវិធីណាមួយដែលអាចឱ្យតតិយជនណាមួយរកឃើញ ដែលនាំឱ្យជននោះប្រើប្រាស់កាតបាន។

៥.៤ នៅពេលម្ចាស់កាតទទួលបានលេខសម្ងាត់ វាគឺជាការទទួលខុសត្រូវរបស់ម្ចាស់កាតដើម្បីធានាថាលេខសម្ងាត់មិនត្រូវបានដឹង ឬរកឃើញដោយបុគ្គលដទៃទៀត ហើយធនាគារឯកទេស អ៊ីអន មិនទទួលខុសត្រូវប្រសិនបើលេខសម្ងាត់ត្រូវបានដឹង និងរកឃើញដោយតតិយជន។ ម្ចាស់កាតត្រូវធានាថា ធនាគារឯកទេស អ៊ីអន មិនជាប់ពាក់ព័ន្ធទៅលើរាល់ការទាមទារ និងការទទួលខុសត្រូវពីគ្រប់ភាគី ដែលកើតឡើងពីការប្រើប្រាស់លេខសម្ងាត់ទោះបីជាមានការអនុញ្ញាត ឬផ្សេងពីនេះ។

**ប្រការ ៦ ការបង្ហាញលេខសម្ងាត់ ឬការបាត់ ចោរលួច ឬការប្រើប្រាស់កាតដោយគ្មានការអនុញ្ញាត**

៦.១ វាជាលក្ខខណ្ឌមូលដ្ឋានដែលម្ចាស់កាតត្រូវប្រើប្រាស់ដោយការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ដើម្បីការពារការបង្ហាញលេខសម្ងាត់ទៅជន ដែលគ្មានការអនុញ្ញាត ការបាត់ ឬចោរលួច ឬការប្រើប្រាស់កាតដោយគ្មានការអនុញ្ញាត។ ប្រការនេះរាប់បញ្ចូលតែមិនកំណត់នូវវិធានការនានា ដូចជាការផ្លាស់ប្តូរញឹកញាប់នៃលេខសម្ងាត់របស់ម្ចាស់កាត ហើយជៀសវាងម្ចាស់កាតប្រើប្រាស់តម្លៃនៃលេខសម្ងាត់ ដែលងាយស្រួលទាយ ឬងាយរកឃើញដោយអ្នកដទៃ ឧទាហរណ៍ដូចជាថ្ងៃខែឆ្នាំកំណើតជាដើម។

៦.២ ការបង្ហាញលេខសម្ងាត់ទៅជន ដែលគ្មានការអនុញ្ញាត ការបាត់ ឬចោរលួច ឬការប្រើប្រាស់កាតដោយគ្មានការអនុញ្ញាតណាមួយត្រូវរាយការណ៍ភ្លាមៗតាមរយៈទូរស័ព្ទ ឬសារអេឡិចត្រូនិកទៅធនាគារឯកទេស អ៊ីអន ភ្ជាប់ជាមួយលិខិតជាលាយលក្ខណ៍អក្សរទៅធនាគារឯកទេស អ៊ីអន។ ម្ចាស់កាតត្រូវប្តឹងភ្លាមៗទៅសមត្ថកិច្ច ពាក់ព័ន្ធហេតុការណ៍ដែលកើតឡើងណាមួយ និងបញ្ជូនឯកសារថតចម្លងនៃរបាយការណ៍ទៅសមត្ថកិច្ចជូនទៅឱ្យធនាគារឯកទេស អ៊ីអន ភ្លាមៗ និងក្នុងករណីណាមួយក៏ដោយក៏មិនត្រូវយឺតជាងប្រាំពីរ (៧) ថ្ងៃចាប់ពីថ្ងៃដែលបានដឹងពីព្រឹត្តិការណ៍ដែលបានកើតឡើង លើកលែងក្នុងករណីដែលមានហេតុផល និងភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញពីផលវិបាកដែលមិនអាចឱ្យខ្លួនជូនដំណឹងបាន។

៦.៣ រហូតទាល់តែ និងលុះត្រាតែការជូនដំណឹងដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរពីការបាត់ ឬចោរលួចកាតពីម្ចាស់កាតយោងតាមប្រការ ៦.២ បានទទួលដោយ ធនាគារឯកទេស អ៊ីអន ម្ចាស់កាតនៅតែទទួលខុសត្រូវលើសោហ៊ុយ ដែលកើតឡើងមុនការជូនដំណឹងខាងលើទោះបីការប្រើប្រាស់ត្រូវបានអនុញ្ញាត ឬមិនអនុញ្ញាតដោយម្ចាស់កាត។

ការទទួលខុសត្រូវរបស់ម្ចាស់កាតត្រូវកម្រិតមកត្រឹម១០០ដុល្លារ (១០០ USD) សម្រាប់សោហ៊ុយ ដែលកើតឡើងបន្ទាប់ពីការរាយការណ៍អំពីការបាត់ ឬចោរលួចកាត ប្រសិនបើម្ចាស់កាតធ្លាប់បានអនុវត្តការប្រើប្រាស់ដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ក្នុងការការពារលេខសម្ងាត់ពីជន ដែលគ្មានការអនុញ្ញាត ការបាត់ ឬចោរលួច ឬការប្រើប្រាស់កាតដោយគ្មានការអនុញ្ញាតណាមួយ ហើយបានរាយការណ៍ពីការបាត់ ឬចោរលួចភ្លាមៗតាមដែលអាចធ្វើទៅបាន ក្នុងករណីដែលម្ចាស់កាតមិនបានធ្វើសកម្មភាពមិនស្មោះត្រង់ពាក់ព័ន្ធនឹងការបាត់ ឬចោរលួចកាតនោះ។

៦.៤ ដោយមិនផ្ទុយពីសិទ្ធិរបស់ ធនាគារឯកទេស អ៊ីអន ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ និងថ្វីបើម្ចាស់កាតបានអនុវត្តសិទ្ធិដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ក្នុងការការពារ ការបាត់ ឬចោរលួចកាត និងរាយការណ៍អំពីការបាត់ និងចោរលួចកាតនេះ ស្របតាមប្រការ ៦.២ នៃបទបញ្ញត្តិ និងលក្ខខណ្ឌ ម្ចាស់កាតនៅតែទទួលខុសត្រូវក្នុងការបង់ប្រាក់ទៅឱ្យ ធនាគារឯកទេស អ៊ីអន ទៅតាមស្ថានភាពដូចខាងក្រោម៖

(ក) ម្ចាស់កាតបានធ្វើសកម្មភាពមិនស្មោះត្រង់ ដោយគាត់បានជាប់ពាក់ព័ន្ធនឹងការទទួលយកទំនិញ និងសេវាកម្មដែលផ្តល់ដោយពាណិជ្ជករណាមួយ ឬការដកសាច់ប្រាក់ជាមុន ដែលរងប៉ះពាល់តាម រយៈការប្រើប្រាស់កាតដោយបុគ្គលណាមួយ ឬ

(ខ) ម្ចាស់កាតខកខានក្នុងការជូនដំណឹងមកធនាគារឯកទេស អ៊ីអន ភ្លាមៗ តាមដែលអាចធ្វើទៅបាននៅពេលរកឃើញថាកាតត្រូវបានបាត់ ឬលួច។

៦.៥ នៅពេលកាតបាត់ ឬត្រូវគេលួចបានរកឃើញវិញ ម្ចាស់កាតមិនត្រូវប្រើប្រាស់ ឬព្យាយាមប្រើប្រាស់កាតនោះទេ ប៉ុន្តែភ្លាមៗនោះត្រូវកាត់លើបន្ទះមេកានិច និងបន្ទះកាតហើយយកកាតដែលបានមកវិញប្រគល់ទៅឱ្យធនាគារឯកទេស អ៊ីអន។

៦.៦ ធនាគារឯកទេស អ៊ីអន មិនមានកាតព្វកិច្ចចេញកាតជំនួសទេ ប៉ុន្តែធនាគារឯកទេស អ៊ីអន អាចចេញកាតជំនួសឱ្យទៀតបាន លុះត្រាតែម្ចាស់កាតយល់ព្រម និងទូទាត់ថ្លៃចំណាយ ឬសោហ៊ុយផ្សេងៗទាក់ទងនឹងការចេញកាតជំនួសនេះ ដែលថ្លៃចំណាយ ឬសោយហ៊ុនផ្សេងៗ នឹងត្រូវកំណត់ដោយធនាគារឯកទេស អ៊ីអន។

**ប្រការ ៧ កាតគឺជាទ្រព្យសម្បត្តិរបស់ធនាគារឯកទេស អ៊ីអន**

៧.១ កាតគឺត្រូវស្ថិតនៅជាទ្រព្យសម្បត្តិរបស់ធនាគារឯកទេស អ៊ីអន និងត្រូវប្រគល់ទៅឱ្យធនាគារឯកទេស អ៊ីអន ភ្លាមៗដោយយោងតាមសំណើរបស់ធនាគារឯកទេស អ៊ីអន ឬភ្នាក់ងារមានសមត្ថកិច្ច។

៧.២ ផ្អែកលើការផុតកំណត់នៃកាត ម្ចាស់កាតត្រូវប្រគល់កាតដែលផុតកំណត់ទៅធនាគារឯកទេស អ៊ីអន ភ្លាម និងស្នើសុំកាតថ្មីពីធនាគារឯកទេស អ៊ីអន ដែលធនាគារឯកទេស អ៊ីអន មានឆន្ទានុសិទ្ធិផ្តាច់មុខលើការ អនុម័តជាថ្មីនេះ។

**ប្រការ ៨ កាតមិនត្រូវផ្ទេរ ឬបញ្ចាំ**

៨.១ កាតមិនត្រូវធ្វើការផ្ទេរ និងត្រូវប្រើប្រាស់ដោយម្ចាស់កាតតែមួយគត់។

៨.២ កាតមិនត្រូវដាក់បញ្ចាំជាប្រាតិភោគដោយម្ចាស់កាតក្នុងគោលបំណងណាមួយ។

**ប្រការ ៩ កាតមិនត្រូវប្រើប្រាស់ក្នុងសកម្មភាពខុសច្បាប់**

៩.១ កាតមិនត្រូវយកទៅប្រើប្រាស់ក្នុងសកម្មភាពខុសច្បាប់ ដូចជាប្រតិបត្តិការតាមប្រព័ន្ធអ៊ិនធើណេតខុសច្បាប់ និងការភ្នាល់ ឬល្បែងស៊ីសងខុសច្បាប់។

៩.២ ធនាគារឯកទេស អ៊ីអន ត្រូវបញ្ចប់អ៊ីអនកាតភ្លាមៗ ប្រសិនបើរកឃើញថាម្ចាស់កាតបានប្រើប្រាស់កាតក្នុងសកម្មភាពខុសច្បាប់។

**ប្រការ ១០ ប្រតិបត្តិការជាមួយពាណិជ្ជករ**

១០.១ ធនាគារឯកទេស អ៊ីអន ត្រូវមានសិទ្ធិបង្ហាញព័ត៌មានទៅពាណិជ្ជករណាមួយ ដែលកាន់ប័ណ្ណ ឬស្ថាប័នដែលជាសមាជិករបស់ម៉ាកប័ណ្ណឥណទានអន្តរជាតិ នូវលេខគណនីរបស់ម្ចាស់កាត និងព័ត៌មានផ្សេងៗដែលអាចចាំបាច់សម្រាប់សម្របសម្រួលក្នុងការប្រើប្រាស់កាត ឬដំណើរការនៃប្រតិបត្តិការដែលប៉ះពាល់ ឬត្រូវប៉ះពាល់តាមរយៈការប្រើប្រាស់កាត។

១០.២ ដោយមិនផ្ទុយពីប្រការ ១០.១ ក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ ធនាគារឯកទេស អ៊ីអន មិនត្រូវទទួលខុសត្រូវចំពោះការបដិសេធរបស់ពាណិជ្ជករ ឬសមាជិករបស់ម៉ាកប័ណ្ណឥណទានអន្តរជាតិ ដើម្បីផ្តល់ ឬទទួលប័ណ្ណ ឬភាពខ្វះខាត ឬមិនគ្រប់គ្រាន់នៃទំនិញ ឬសេវាកម្មដែលផ្គត់ផ្គង់ទៅឱ្យម្ចាស់កាត ដោយពាណិជ្ជករណាម្នាក់ឡើយ។ រាល់បណ្តឹងធ្វើឡើងដោយម្ចាស់កាត ត្រូវដោះស្រាយដោយផ្ទាល់ជាមួយពាណិជ្ជករ ឬសមាជិកនៃស្ថាប័នម៉ាក ប័ណ្ណឥណទានអន្តរជាតិដែលពាក់ព័ន្ធ ហើយគ្មានបណ្តឹងណាមួយធ្វើទៅលើពាណិជ្ជករ ឬសមាជិកនៃស្ថាប័នម៉ាកប័ណ្ណឥណទានអន្តរជាតិ នាំឱ្យម្ចាស់កាតមានសិទ្ធិរៀបចំបណ្តឹងបន្ថែមទាមទារទៅធនាគារឯកទេស អ៊ីអន ឬមានសិទ្ធិបដិសេធការបង់ប្រាក់ទៅឱ្យធនាគារឯកទេស អ៊ីអន ពាក់ព័ន្ធនឹងគណនី ដែលមានបណ្តឹងណាមួយ ឬទោះបីស្ថិតនៅក្រោមកាលៈទេសៈណាក៏ដោយ។

**ប្រការ ១១ ការដកសាច់ប្រាក់ជាមុន ការប្រាក់ និងការប្តូររូបិយប័ណ្ណសម្រាប់ប្រតិបត្តិការបរទេស**

១១.១ ការដកសាច់ប្រាក់ជាមុន នាំឱ្យមានការគិតសោហ៊ុយនៃប្រតិបត្តិការដកយកសាច់ប្រាក់ជាមុនណាមួយ ដែលបានធ្វើឡើង។ ការប្រាក់នឹងត្រូវបានបង្គរទុកផ្អែកទៅលើទឹកប្រាក់ ដែលបានដកយកជាមុនដោយគណនាប្រចាំថ្ងៃជាមូលដ្ឋានចាប់ពីកាលបរិច្ឆេទនៃការដករហូតដល់កាលបរិច្ឆេទដែលត្រូវទូទាត់។ ប្រសិនបើម្ចាស់កាតមិនជ្រើសរើសការបង់ប្រាក់ទាំងអស់ ការប្រាក់នឹងត្រូវគិតទៅលើចំនួនទឹកប្រាក់ប្រចាំថ្ងៃជាមូលដ្ឋាន ចាប់ពីកាលបរិច្ឆេទនៃការដកយកសាច់ប្រាក់ជាមុនរហូតដល់កាលបរិច្ឆេទបិទការទូទាត់ (បច្ចុប្បន្នគឺនៅថ្ងៃទី(១០) នៃខែនីមួយៗ ប៉ុន្តែវាអាចមានការផ្លាស់ប្តូរនៅពេលណាមួយតាមការកំណត់របស់ធនាគារឯកទេស អ៊ីអន)។ បន្ថែមពីនេះទៅទៀត ការប្រាក់នឹងត្រូវគណនាប្រចាំថ្ងៃជាមូលដ្ឋានចាប់ពីថ្ងៃបិទការទូទាត់នោះរហូតដល់ថ្ងៃបិទការទូទាត់បន្ទាប់។ ចំនួនសាច់ប្រាក់ដកយកជាមុនដែលពាក់ព័ន្ធ នឹងសោហ៊ុយ និងអត្រាការប្រាក់នឹងត្រូវកំណត់ដោយធនាគារឯកទេស អ៊ីអន ពីពេលមួយទៅពេលមួយ និងជូនដំណឹងទៅម្ចាស់កាតតាមមធ្យោបាយណាមួយដែល ធនាគារឯកទេស អ៊ីអន យល់ឃើញថាសមស្រប។

១១.២ សម្រាប់ប្រតិបត្តិការ ដែលធ្វើឡើងក្រៅប្រទេសពាក់ព័ន្ធនឹងរូបិយប័ណ្ណបរទេស ការគណនាសោហ៊ុយដំបូងត្រូវបំលែងជាដុល្លារអាមេរិក នៅអត្រាប្តូរប្រាក់ ដែលកំណត់ដោយម៉ាកកាតឥណទានអន្តរជាតិតាមឆន្ទានុសិទ្ធិផ្តាច់មុខមុននឹងកាត់ប្រាក់ចេញពីគណនី អ៊ីអនកាត។

១១.៣ ម្ចាស់កាតអាចប្រើប្រាស់សេវាកម្មដកយកសាច់ប្រាក់ជាមុននៅម៉ាស៊ីន ATM នៃធនាគារណាមួយ ឬ ស្ថាប័នហិរញ្ញវត្ថុ ធនាគារឯកទេស អ៊ីអន ដែលរៀបចំឡើងសម្រាប់ប្រើប្រាស់ម៉ាស៊ីនATM ដូចដែលមានបង្ហាញដោយធនាគារ ឬស្ថាប័នហិរញ្ញវត្ថុ (ក្នុងករណីចំនួនសាច់ប្រាក់ត្រូវជាកម្មវត្ថុនៃការដកប្រើប្រាស់ប្រចាំថ្ងៃទៅតាមការកំណត់របស់ធនាគារ ឬស្ថាប័នហិរញ្ញវត្ថុនោះ។

១១.៤ ការប្រើប្រាស់កាតដោយម្ចាស់កាតដើម្បីទទួលបានការដកប្រាក់ជាមុនត្រូវបានសន្មតថា មានចែងនៅក្នុងកិច្ចព្រមព្រៀង ដែលម្ចាស់កាតត្រូវបង់ការប្រាក់ទៅលើការដកសាច់ប្រាក់ជាមុនណាមួយ និងសោហ៊ុយនៃសាច់ប្រាក់ដកយកជាមុន ដូចដែលបានកំណត់ដោយធនាគារឯកទេស អ៊ីអន ពីពេលមួយទៅពេលមួយ ដែលមានចែងនៅក្នុងប្រការនេះ។

១១.៥ ព័ត៌មានលម្អិតស្តីពីសោហ៊ុយនៃការដកប្រាក់ជាមុន និងការប្រាក់ត្រូវបានកំណត់នៅក្នុង តារាងតម្លៃសេវារបស់ធនាគារឯកទេស អ៊ីអន។ ធនាគារឯកទេស អ៊ីអន មានសិទ្ធិកែប្រែរចនាសម្ព័ន្ធនៃតម្លៃសេវា ឬកម្រៃផ្សេងៗ។

**ប្រការ ១២ ការទិញលក់រាយដែលបានធ្វើនៅក្រៅប្រទេសកម្ពុជា**

១២.១ ប្រសិនបើប្រតិបត្តិការមួយត្រូវបានធ្វើឡើងនៅក្រៅប្រទេសកម្ពុជាជារូបិយប័ណ្ណបរទេស ម៉ាកប័ណ្ណឥណទានអន្តរជាតិ នឹងបំលែងប្រតិបត្តិការនេះដោយផ្អែកតាមប្រភេទកាតដែលបានប្រើទៅជាប្រាក់ដុល្លារក្នុងអត្រាប្តូរប្រាក់ប្រហាក់ប្រហែលនឹងអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទជាក់ស្តែងដែលកំណត់ដោយម៉ាក ប័ណ្ណឥណទានអន្តរជាតិ។ សោហ៊ុយនៃការបំលែងរូបិយប័ណ្ណបរទេសត្រូវគិតបញ្ចូល និងបន្ថែមទៅក្នុងសោហ៊ុយនៃប្រតិបត្តិការរបស់អ្នក។ អត្រាសោហ៊ុយនៃការបំលែងរូបិយប័ណ្ណ មានចែងនៅក្នុងតារាងតម្លៃរបស់ ធនាគារឯកទេស អ៊ីអន។

១២.២ ម្ចាស់កាតយល់ស្របថា បើមានវិវាទណាមួយពាក់ព័ន្ធនឹងអត្រាប្តូរប្រាក់ដែលបានកំណត់ដោយម៉ាក ប័ណ្ណឥណទានអន្តរជាតិទៅលើប្រតិបត្តិការណាមួយរបស់ម្ចាស់កាត ធ្វើឡើងនៅក្រៅប្រទេសកម្ពុជា ធនាគារឯកទេស អ៊ីអន នឹងមិនទទួលខុសត្រូវដោះស្រាយវិវាទនោះ ក្នុងនាមម្ចាស់កាតជាមួយនឹងម៉ាក ប័ណ្ណឥណទានអន្តរជាតិឡើយ។

**ប្រការ ១៣ ការប្រើប្រាស់ប្រតិបត្តិការឥណទានតាមអ៊ិនធើណេត**

ប្រសិនបើម្ចាស់កាតប្រើកាតដើម្បីទិញទំនិញ និង/ឬសេវាកម្មតាមរយៈគេហទំព័រអនឡាញ ឬគេហទំព័រណាមួយ ម្ចាស់កាតត្រូវទទួលខុសត្រូវទាំងស្រុងចំពោះសុវត្ថិភាពក្នុងការប្រើប្រាស់នោះគ្រប់ពេលវេលា។ ម្ចាស់កាតយល់ស្របថាការបញ្ចូលព័ត៌មាននៃកាតទៅក្នុងអ៊ិនធើណេត នឹងត្រូវចាត់ទុកជាភស្តុតាងគ្រប់គ្រាន់នៃភាពត្រឹមត្រូវក្នុងការណែនាំឱ្យមានប្រតិបត្តិការនោះ។ ធនាគារឯកទេស អ៊ីអន មិនមានកាតព្វកិច្ចផ្ទៀងផ្ទាត់អត្តសញ្ញាណ ឬសិទ្ធិរបស់បុគ្គលណាម្នាក់ ដែលបានបញ្ចូលព័ត៌មាននៃកាតរបស់ម្ចាស់កាតឡើយ ហើយធនាគារឯកទេស អ៊ីអន មិនទទួលខុសត្រូវចំពោះការធ្វើសកម្មភាពនៃការប្រើប្រាស់ព័ត៌មាននៃកាតឡើយ ដោយមិនគិតថាតើបុគ្គលណា ដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ ហើយក៏មិនគិតពីស្ថានភាព ដែលត្រូវអនុវត្តក្នុងពេលនៃប្រតិបត្តិការនេះឡើយ។
ទោះជាយ៉ាងណា ធនាគារឯកទេស អ៊ីអន មានសិទ្ធិមិនអនុវត្តប្រតិបត្តិការណាមួយនៅ
លើអ៊ិនធើណេត ប្រសិនបើធនាគារឯកទេស អ៊ីអន មានមូលហេតុត្រឹមត្រូវ និងសង្ស័យពីភាពមិនត្រឹមត្រូវនៃប្រតិបត្តិការនោះ ឬប្រសិនបើធនាគារឯកទេស អ៊ីអន យល់ថាវាខុសច្បាប់ ឬមិនត្រឹមត្រូវដោយសារហេតុផលផ្សេងៗទៀត។

**ប្រការ ១៤ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការគិតសេវា និង/ឬកម្រៃផ្សេង។**

១៤.១ បន្ថែមពីលើការប្រាក់ ម្ចាស់កាតត្រូវតែបង់តម្លៃសេវា និងកម្រៃផ្សេងៗទាក់ទងនឹងកាត។ សេចក្តីលម្អិតនៃតម្លៃសេវា ត្រូវបានកំណត់នៅក្នុងតារាងតម្លៃសេវារបស់ធនាគារឯកទេស អ៊ីអន។ ធនាគារឯកទេស អ៊ីអន មានសិទ្ធិកែប្រែរចនាសម្ព័ន្ធ ថ្លៃសេវា ឬផ្នែកណាមួយនៃកម្រៃនេះ។

ធនាគារឯកទេស អ៊ីអន នឹងផ្តល់ដំណឹងដល់ម្ចាស់កាតក្នុងរយៈពេលសាមសិប (៣០) ថ្ងៃជាមុន សម្រាប់ការផ្លាស់ប្តូរណាមួយទាក់ទងនឹងតម្លៃ សេវា និងកម្រៃផ្សេងៗ ដូចដែលមានចែងលម្អិតនៅក្នុងតារាងតម្លៃសេវាកម្មរបស់ធនាគារឯកទេស អ៊ីអន តាមរយៈគេហទំព័ររបស់ធនាគារឯកទេស អ៊ីអន។
ថ្លៃសេវាអាចត្រូវបានគិតកម្រៃ ដោយផ្អែកលើចំនួនភាគរយ ដែលបានកំណត់ទុកជាមុននៃតម្លៃប្រតិបត្តិការ/សមតុល្យ ឬជាថ្លៃសេវាអប្បបរមា ឬទាំងពីរ។
ថ្លៃសេវាទាំងអស់នឹងត្រូវកាត់ចេញពីគណនីភ្លាម ឬបន្ទាប់ពីមានរបាយការណ៍គណនីជាបន្តបន្ទាប់ណាមួយតាមស្ថានភាព ដែលអាចអនុវត្តបាន។

១៤.២ ថ្លៃសេវាទាំងអស់ ដែលបានបង់ស្របតាម ឬទាក់ទងនឹងកាតគឺមិនអាចប្តូរវិញបានឡើយ ទោះស្ថិតក្នុងស្ថានភាពណាក៏ដោយ។

១៤.៣ តម្លៃសេវាកម្ម អត្រាពន្ធ ឬការគិតកម្រៃទាំងអស់អាចប្រែប្រួលនៅពេលណាមួយ និងពីពេលមួយទៅពេលមួយទៀត តាមការសម្រេចចិត្ត និងឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារឯកទេស អ៊ីអន ដោយជូនដំណឹងជាមុនទៅម្ចាស់កាតក្នុងរយៈពេលសាមសិប (៣០)ថ្ងៃប្រតិទិន។ ម្ចាស់កាតត្រូវទទួលខុសត្រូវក្នុងការពិនិត្យមើលតម្លៃចុងក្រោយបំផុតនៃអត្រាការប្រាក់ពន្ធ ឬការគិតតម្លៃនានានៅលើគេហទំព័រ ឬទាក់ទងមកធនាគារឯកទេស អ៊ីអន។

### ប្រការ ១៥ ការបែងចែកការទូទាត់

ការទូទាត់សងត្រូវបានអនុវត្តចំពោះរបាយការណ៍គណនី ដែលមានឋានានុក្រមដូចតទៅ៖ ការប្រាក់នៃការដកសាច់ប្រាក់ ការប្រាក់នៃការលក់រាយ ចំនួនប្រាក់ដែលបានដក ចំនួនប្រាក់នៃការលក់រាយ និងកម្រៃរបស់ធនាគារឯកទេស អ៊ីអន។

### ប្រការ ១៦ ការទូទាត់អប្បបរមា និងការប្រាក់លើការទិញលក់រាយ

១៦.១ ម្ចាស់កាតអាចជ្រើសរើសមិនធ្វើការទូទាត់ទាំងស្រុងក្នុងសមតុល្យបច្ចុប្បន្ន ដែលក្នុងករណីនេះនៅថ្ងៃ ឬមុនកាលបរិច្ឆេទកំណត់ការទូទាត់សងប្រាក់ ម្ចាស់កាតត្រូវបង់ឱ្យ ធនាគារឯកទេស អ៊ីអន នូវចំនួនប្រាក់ អប្បបរមាដែលត្រូវបង់ ដែលបានកំណត់ និងគណនាដូចខាងក្រោម៖

ក) ប្រសិនបើសមតុល្យបច្ចុប្បន្នមិនលើសពីដែនកំណត់ឥណទាន នោះម្ចាស់កាតត្រូវបង់ដប់ភាគរយ (១០%) បង្គត់ឡើងទៅតម្លៃដុល្លារដែលនៅជិតបំផុតនៃសមតុល្យបច្ចុប្បន្ន ឬដប់ប្រាំ (១៥)ដុល្លារ តាមតម្លៃណាដែលខ្ពស់ជាង។ ឬ

ខ) ប្រសិនបើសមតុល្យបច្ចុប្បន្នលើសពីដែនកំណត់ឥណទាន នោះម្ចាស់កាតត្រូវបង់ដប់ភាគរយ (១០%) នៃចំនួនកំណត់ឥណទាន និងចំនួនទឹកប្រាក់ដែលលើសពីចំនួនកំណត់ឥណទាន។

១៦.២ ការទិញលក់រាយទាំងអស់ ដែលមិនមែនជាប្រតិបត្តិការដកសាច់ប្រាក់ជាមុន ) ត្រូវគិតតម្លៃនៅក្នុងគណនីកាតឥណទាន នឹងត្រូវអនុញ្ញាតឱ្យរួចផុតពីការគិតការប្រាក់ក្នុងរយៈពេលកំណត់ ចាប់ពីថ្ងៃធ្វើប្រតិបត្តិការ រហូតដល់ថ្ងៃដែលត្រូវទូទាត់សង ប្រសិនបើរបាយការណ៍គណនីខែមុនត្រូវបានទូទាត់រួចរាល់តាមកាលបរិច្ឆេទកំណត់។

១៦.៣ ប្រសិនបើម្ចាស់កាតជ្រើសរើសមិនទូទាត់នូវទឹកប្រាក់សរុប ការប្រាក់នឹងត្រូវគិតទៅលើ សមតុល្យទឹកប្រាក់ ដែលនៅជំពាក់រួមបញ្ចូលទាំងប្រតិបត្តិការថ្មី ដែលធ្វើឡើងដោយម្ចាស់កាតដោយរាប់ចយក្រោយចាប់ពីពេលដែលកាលបរិច្ឆេទនៃប្រតិបត្តិការនោះបានធ្វើឡើង រហូតដល់បានទូទាត់ប្រាក់គ្រប់ចំនួននៅក្នុងអត្រាដែលកំណត់ដោយ ធនាគារឯកទេស អ៊ីអនពីពេលមួយទៅពេលមួយ និងត្រូវជូនដំណឹងដល់ម្ចាស់កាតតាមដែលធនាគារឯកទេស អ៊ីអន មើលទៅឃើញថាសមរម្យ។

**ប្រការ ១៧ ការពិន័យលើការបង់យឺត**

១៧.១ ការពិន័យលើការបង់យឺតនឹងត្រូវបានអនុវត្ត ប្រសិនបើគ្មានការទូទាត់ត្រូវបានទទួលបន្ទាប់ពីរយៈពេលអនុគ្រោះ ឬប្រសិនបើចំនួនប្រាក់ដែលទទួលបានមុនពេលរយៈពេលអនុគ្រោះមានតិចជាងចំនួនប្រាក់អប្បបរមាដែលត្រូវទូទាត់សង និងត្រូវកំណត់ដូចខាងក្រោម៖

- ថ្ងៃទូទាត់គឺចាប់ពីថ្ងៃទី ០៦ ដល់ថ្ងៃទី ១០ នៃខែនីមួយៈ មួយដុល្លារ ( ១USD )
- ថ្ងៃទូទាត់គឺចាប់ពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៥ នៃខែនីមួយៈ ពីរដុល្លារ ( ២USD )
- ថ្ងៃទូទាត់គឺចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២០ នៃខែនីមួយៈ បីដុល្លារ ( ៣USD )

១៧.២ ការពិន័យលើការបង់យឺត ត្រូវបានគណនាដោយផ្អែកលើស្ថានភាពនៃការទូទាត់ប្រចាំខែរបស់ម្ចាស់កាត ហើយបន្ទាប់មកត្រូវគិតកម្រៃទាំងនោះនៅក្នុងវិក្កយបត្រនៃខែបន្ទាប់។

**ប្រការ ១៨ ភស្តុតាងនៃការជំពាក់ប្រាក់**

១៨.១ ធនាគារឯកទេស អ៊ីអន ត្រូវមានសិទ្ធិទទួលដោយផ្អែកលើ៖

ក ) វិក្កយបត្រនៃការលក់ កំណត់ត្រានៃប្រតិបត្តិការ ប័ណ្ណបញ្ជាក់ឥណទាន វិក្កយបត្រដកប្រាក់ និង/ឬការទូទាត់ផ្សេងៗទៀតដែលមានបង្ហាញ ឬព័ត៌មានផ្សេងៗដែលមាននៅក្នុងប្រតិបត្តិការនៃកាតនោះ និង/ឬ

ខ ) កំណត់ត្រានៃការដកប្រាក់ ឬប្រតិបត្តិការណាមួយរបស់ធនាគារឯកទេស អ៊ីអន ដែលពាក់ព័ន្ធនឹងការប្រើប្រាស់កាត រួមបញ្ចូលទាំង ប៉ុន្តែមិនកំណត់លើប្រតិបត្តិការដែលធ្វើឡើងតាមអ៊ីម៉ែល ឬតាមរយៈទូរស័ព្ទជាភស្តុតាងបញ្ជាក់ពីបំណុលដែលបានកើតឡើងត្រឹមត្រូវដោយម្ចាស់កាត ហើយនឹងត្រូវបានកាត់យកពីគណនីកាតឥណទាន

និងត្រូវកត់ត្រាក្នុងរបាយការណ៍គណនី។

១៨.២ ការទូទាត់ទាំងឡាយសម្រាប់ការទិញទំនិញ និង/ឬសេវាកម្ម និងការដកប្រាក់ដោយការប្រើប្រាស់កាត និងសេវាប្រចាំឆ្នាំទាំងឡាយ ថ្លៃចំណាយផ្សេងៗ ថ្លៃចំណាយបន្ថែមផ្សេងៗ ការប្រាក់ កម្រៃពីការពិន័យលើការបង់យឺត និងថ្លៃសេវាដ៏ទៃទៀត នឹងត្រូវបានកាត់ចេញពីគណនីកាតឥណទាន នៅក្នុងរូបិយប័ណ្ណ ដែលមានក្នុងវិក្កយបត្រ និងត្រូវកត់ត្រាក្នុងរបាយការណ៍គណនី។

១៨.៣ ម្ចាស់កាតយល់ព្រមលើកំណត់ត្រារបស់ធនាគារឯកទេស អ៊ីអន ចំពោះប្រតិបត្តិការណាមួយតាមរយៈការប្រើប្រាស់កាត ត្រូវសន្មតថាជាភស្តុតាង និងចងកាតព្វកិច្ចលើម្ចាស់កាតលើរាល់គោលបំណងទាំងអស់ លុះត្រាតែមានប្រការផ្សេងចែងផ្ទុយពីនេះ។

## ប្រការ ១៩ ការប្រើលើសចំនួនកម្រិតឥណទានដែលបានកំណត់

១៩.១ ម្ចាស់កាតសន្យាថាខ្លួននឹងមិនប្រើប្រាស់កាត ដែលនាំឱ្យចំនួនទឹកប្រាក់ជំពាក់ ធនាគារឯកទេស អ៊ីអន កើនលើសពីចំនួនឥណទានដែលបានអនុម័ត លុះត្រាតែបានទទួលការអនុម័តយល់ព្រមជាមុនពីធនាគារឯកទេស អ៊ីអន ដែលមានចំនួនមិនលើសពី ១០% នៃចំនួនឥណទានដែលបានអនុម័ត។

១៩.២ ក្នុងករណី ដែលមានការប្រើលើសកម្រិតឥណទានដែលបានកំណត់ក្រៅពីចំនួនប្រាក់ ដែលត្រូវបង់ស្របតាមប្រការ ១៦ ម្ចាស់កាតត្រូវបង់បន្ថែមទៅធនាគារឯកទេស អ៊ីអន ឱ្យបានពេញលេញនូវទឹកប្រាក់ ដែលលើសកម្រិតកំណត់ទាំងនោះ បើមិនដូច្នោះនឹងត្រូវបានចាត់ទុកថាការប្រើប្រាស់កាតត្រូវបានបញ្ចប់ ហើយបញ្ញត្តិទាក់ទងទៅនឹងការបញ្ចប់ការប្រើប្រាស់កាតមានចែងក្នុងប្រការ ២១ ត្រូវយកមកអនុវត្ត។

១៩.៣ ក្នុងករណីការកំណត់ឥណទានត្រូវបានប្រើលើសកម្រិត ថ្លៃប្រើប្រាស់លើស ដែលត្រូវបានកំណត់ជាតារាងតម្លៃរបស់ធនាគារឯកទេស អ៊ីអន នឹងត្រូវយកមកអនុវត្ត។

## ប្រការ ២០ ការបង់ប្រាក់

២០.១ ការទូទាត់ទាំងឡាយចំពោះធនាគារឯកទេស អ៊ីអន ត្រូវធ្វើឡើងជារូបិយប័ណ្ណ ដែលមានបញ្ជាក់ក្នុង វិក្កយបត្រ។

២០.២ ការទូទាត់ធ្វើឡើងដោយម្ចាស់កាតទៅ ធនាគារឯកទេស អ៊ីអន មិនត្រូវចាត់ទុកថាបានធ្វើឡើងឡើយ រហូតទាល់តែហិរញ្ញប្បទាន ដែលពាក់ព័ន្ធត្រូវបានទទួល និងទទួលស្គាល់ដោយធនាគារឯកទេស អ៊ីអន ហើយបានដាក់បញ្ចូលការទូទាត់នោះទៅក្នុងប្រព័ន្ធកំណត់ត្រាកុំព្យូទ័ររបស់ធនាគារឯកទេស អ៊ីអននៅថ្ងៃ ដែលវិក្កយបត្រនៃការទូទាត់បានចេញដោយធនាគារឯកទេស អ៊ីអន។ យោងតាមឆន្ទានុសិទ្ធិរបស់ធនាគារឯកទេស អ៊ីអន លើការលើកលែងចោលនូវប្រការទាំងឡាយខាងមុខទៀត ប្រការ

ដែលបានលើកលែងនោះក៏ត្រូវយកមកអនុវត្តសម្រាប់គោលបំណង កំណត់អំពីចំនួនទឹកប្រាក់ ដែលអាចប្រើប្រាស់ បាននៅក្នុងកម្រិតឥណទាន របស់ម្ចាស់អ៊ីអនកាត។

នៅពេលដែលម្ចាស់កាតបានអនុវត្តតាមការណែនាំដែលអនុញ្ញាតឱ្យមានការទូទាត់ប្រាក់ជំពាក់ ដែលដល់កំណត់សងដោយកាត់យកប្រាក់ដោយផ្ទាល់ ឬដោយស្វ័យប្រវត្តិពីគណនីឥណពន្ធម្ចាស់កាតដោយមិនធ្វើការផ្លាស់ប្តូរ អនុញ្ញាតឱ្យធនាគារឯកទេស អ៊ីអន ដាក់ទិន្នន័យវិក្កយបត្រទៅធនាគារដើម្បីធ្វើការកាត់ប្រាក់ ដែលដល់កំណត់សងពីគណនីកាតឥណទាន ពីគណនីធនាគាររបស់ម្ចាស់កាតនៅថ្ងៃដល់កំណត់សង។

**ប្រការ ២១ ករណីមានកំហុស**

២១.១ ករណីដែលហេតុការណ៍ណាមួយដូចខាងក្រោមបានកើតឡើង៖

ក) ប្រសិនបើចំនួនប្រាក់ដល់កំណត់សងដែលម្ចាស់កាតត្រូវបង់ឱ្យធនាគារឯកទេស អ៊ីអន នៅពេលណាមួយតាមគណនីកាតឥណទាន

ខ) ប្រសិនបើការបង់ប្រាក់ដល់កំណត់សង ដែលម្ចាស់កាតត្រូវបង់ឱ្យធនាគារឯកទេស អ៊ីអន ហួសកាលកំណត់សងលើគណនីផ្សេងទៀត។

គ) ប្រសិនបើម្ចាស់កាតបំពានបញ្ញត្តិ និងលក្ខខណ្ឌ ឬផ្នែកណាមួយនោះដែលបានកំណត់ក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ។

ឃ) ប្រសិនបើម្ចាស់កាតប្រើកាតសម្រាប់សកម្មភាពមិនស្របច្បាប់ណាមួយដូចជា ការភ្នាល់តាមអនឡាញដោយខុសច្បាប់ជាដើម។

ង) ប្រសិនបើម្ចាស់កាតចាកចេញពីប្រទេសកម្ពុជាដើម្បីរស់នៅកន្លែងផ្សេងទៀត។

ច) ប្រសិនបើម្ចាស់កាតស្លាប់ ឬត្រូវបានប្រកាសថាជាអសមត្ថជន។

ឆ) ប្រសិនបើម្ចាស់កាត នឹងត្រូវបានប្រកាសថាក្ស័យធន។

ជ) ប្រសិនបើម្ចាស់កាត មិនអាចសងបំណុលរបស់ខ្លួនបាននៅពេលដល់កំណត់សង ឬក្លាយទៅជាក្ស័យធន។

ឈ) ប្រសិនបើធនាគារឯកទេស អ៊ីអន មិនស្គាល់កន្លែងស្នាក់នៅរបស់ម្ចាស់កាត។

ញ) ប្រសិនបើម្ចាស់កាតមានបំណងបញ្ចប់ការប្រើប្រាស់កាត ប៉ុន្តែម្ចាស់កាតមិនទាន់ទូទាត់បំណុលដែលជំពាក់ទាំងអស់ជូន ធនាគារឯកទេស អ៊ីអន។

ត) ប្រសិនបើធនាគារឯកទេស អ៊ីអន តាមឆន្ទានុសិទ្ធិរបស់ខ្លួនមិនព្រមចេញកាតជំនួស ឬកាតបន្តជាថ្មី។

ថ) ប្រសិនបើធនាគារឯកទេស អ៊ីអន តាមឆន្ទានុសិទ្ធិរបស់ខ្លួនសម្រេចលុបចោល ឬបញ្ឈប់ការប្រើប្រាស់កាត នោះការប្រើប្រាស់កាតនឹង

ត្រូវបញ្ចប់ភ្លាម ហើយទឹកប្រាក់ដែលនៅជំពាក់ទាំងអស់ នឹងក្លាយទៅជាដល់កំណត់សងភ្លាមៗ ហើយម្ចាស់កាតត្រូវសងចំនួនទាំងនោះឱ្យធនាគារឯកទេស អ៊ីអន ហើយបំណុលបន្ថែមទៀតទាំងឡាយដែលកើតឡើងលើគណនីកាតឥណទានបន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ចប់នេះ រួមបញ្ចូលទាំងការប្រាក់ ថ្លៃសេវា និងកម្រៃផ្សេងទៀតនឹងក្លាយទៅជាដល់កំណត់សង និងត្រូវសងនៅពេលដែលបំណុលទាំងនោះត្រូវបានបញ្ចូលក្នុងគណនីកាតឥណទាន។ ម្ចាស់កាតនៅតែបន្តចងកាតព្វកិច្ចដោយបញ្ញត្តិ និងលក្ខខណ្ឌ ដូចមានចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះដដែល ទោះបីជាមានការបញ្ចប់ការប្រើប្រាស់កាតដោយ ធនាគារឯកទេស អ៊ីអន ដោយមូលហេតុណាក៏ដោយ ។

២១.២ នៅក្នុងករណី ដែលធនាគារឯកទេស អ៊ីអន ទទួលបានសាលក្រមសម្រាប់ប្រាក់ ដែលដល់កំណត់សងណាមួយ ការប្រាក់ ប្រាក់ពិន័យសម្រាប់ការបង់យឺតយ៉ាវ ឬការគិត សេវាផ្សេងៗទៀតត្រូវបន្តទូទាត់ចាប់ពីកាលបរិច្ឆេទនៃការចេញសាលក្រម រហូតទាល់តែមានការទូទាត់ពេញលេញបានផ្ញើរួចរាល់ទៅឱ្យធនាគារឯកទេស អ៊ីអន។

២១.៣ ការបំពានលក្ខខណ្ឌ ឬកំហុសណាមួយប្រព្រឹត្តដោយម្ចាស់កាតទាក់ទងនឹងគណនីកាតឥណទានមួយ មានន័យដូចគ្នានឹងការរំលោភបំពាន ឬកំហុសណាមួយប្រព្រឹត្តដោយម្ចាស់កាតទាក់ទងនឹងគណនីកាតឥណទានមួយទៀត។ បញ្ញត្តិនេះមានន័យថាករណីដែលការបំពានណាមួយ ឬកំហុសណាមួយប្រព្រឹត្តដោយម្ចាស់កាតទាក់ទងនឹងគណនីកាតឥណទានមួយ ដែលគណនីកាតឥណទាននោះត្រូវមានសំណងឱ្យធនាគារឯកទេស អ៊ីអន នោះធនាគារឯកទេស អ៊ីអន ក៏មានសិទ្ធិទៅយកសំណងនោះពីគណនីកាតឥណទានមួយទៀតរបស់ម្ចាស់កាតបានដែរ។

### ប្រការ ២២ ការរួមបញ្ចូលគ្នានៃគណនីឥណទាន និងការទូទាត់សង

បន្ថែមពីលើសិទ្ធិទៅក្នុងការទូទាត់ ឬសិទ្ធិផ្សេងទៀតដែលកំណត់ដោយច្បាប់ទៅលើ ធនាគារឯកទេស អ៊ីអន តាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួននៅពេលណាមួយ ធនាគារឯកទេស អ៊ីអន ជូនដំណឹងប្រាំពីរ( ៧ )ថ្ងៃជាមុនទៅម្ចាស់កាតអំពីសិទ្ធិបង្រួម ឬបញ្ចូលគ្នានូវគណនីទាំងអស់ ឬណាមួយរបស់ម្ចាស់កាត ដែលមានឥណទានជាមួយធនាគារឯកទេស អ៊ីអន ដោយពុំចាំបាច់គិតដល់ទីកន្លែង និងរូបិយប័ណ្ណជាដុល្លារអាមេរិក ឬរូបិយប័ណ្ណផ្សេងទៀតណាមួយ ឬការទូទាត់សង ឬផ្ទេរប្រាក់មួយចំនួនណាមួយទៅក្នុងឥណទាននៃគណនីទាំងនោះ រួមមានគណនីរួម ដែលមានម្ចាស់កាតបន្ថែមដើម្បីកាត់យកប្រាក់ ដែលជំពាក់ធនាគារឯកទេស អ៊ីអន ពីគណនីណាមួយរបស់ម្ចាស់កាតដែលមានជាមួយ ធនាគារឯកទេស អ៊ីអន ដោយពុំចាំបាច់គិតដល់ទីកន្លែង និងរូបិយប័ណ្ណជាដុល្លារអាមេរិក ឬរូបិយប័ណ្ណផ្សេងទៀតណាមួយ និងអាចធ្វើដូច្នោះទោះបីជាសមតុល្យនៅលើ

គណនីនោះ និងបំណុលដែលមានមិនស្ថិតក្នុងរូបិយប័ណ្ណដូចគ្នា ហើយម្ចាស់កាត អនុញ្ញាតឱ្យធនាគារឯកទេស អ៊ីអន ធ្វើការបញ្ចូលគ្នានូវគណនីទូទាត់សង ឬផ្ទេរ ដោយគិតតាមអត្រាប្តូរប្រាក់របស់ ធនាគារឯកទេស អ៊ីអន ដែលត្រូវកំណត់ និង សម្រេចដោយឆន្ទានុសិទ្ធិរបស់ធនាគារឯកទេស អ៊ីអន។

**ប្រការ ២៣ ការបញ្ចប់ការប្រើប្រាស់កាតដោយម្ចាស់កាត**

២៣.១ ម្ចាស់កាតអាចនៅពេលណាមួយ បន្ទាប់ពីការទទួលយក និង/ឬការ ប្រើប្រាស់កាត បញ្ចប់ការប្រើប្រាស់កាតដោយជូនដំណឹងជាលាយលក្ខណ៍ អក្សរទៅធនាគារឯកទេស អ៊ីអន និងប្រគល់កាតនោះដោយកាត់ទទឹង លើម៉ាញ៉េទិច និងកាត់ឈីបនៃកាតនោះឱ្យទៅ ធនាគារឯកទេស អ៊ីអន។ នៅពេលធនាគារឯកទេស អ៊ីអន បានទទួល កាតនោះនឹងត្រូវបានចាត់ ទុកថាបានបញ្ចប់ការប្រើប្រាស់ ហើយបញ្ញត្តិទាក់ទងទៅនឹងការបញ្ចប់ ការប្រើប្រាស់ក្នុងប្រការ ២៣ នេះនឹងត្រូវបានអនុវត្ត។

២៣.២ ម្ចាស់កាតគឺអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការជូនដំណឹងដល់តតិយជន ណាមួយ ដើម្បីលុបចោល សេចក្តីណែនាំអំពីការអនុញ្ញាតជាមុនបន្ទាប់ ពីមានការបញ្ចប់ការប្រើប្រាស់កាតឥណទាន។

២៣.៣ កាតបន្ថែម ដែលចេញរួមគ្នា និងកាតដែលពាក់ព័ន្ធត្រូវបានបញ្ចប់ការ ប្រើប្រាស់ជារួម ហើយលក្ខណៈពិសេស ផលប្រយោជន៍ ពិន្ទុ រង្វាន់ និង លេខកូដទាំងអស់នឹងត្រូវបញ្ឈប់។

២៣.៤ គ្មានសំណងប្រចាំឆ្នាំ ឬផ្នែកណាមួយត្រូវបានធ្វើឡើងឡើយ ហើយម្ចាស់ កាតនៅតែទទួលខុសត្រូវចំពោះបំណុលទាំងឡាយ សោហ៊ុយកម្រៃការ ប្រាក់ និង/ឬប្រតិបត្តិការដែលបានធ្វើតាមរយៈកាតឥណទាន រួមទាំង ការប្រតិបត្តិការ ដែលមិនត្រូវបានកត់ត្រានៅក្នុងគណនីកាតឥណទាន នៅកាលបរិច្ឆេទនៃការបញ្ចប់ការប្រើប្រាស់កាត។

**ប្រការ ២៤ ការកែប្រែផ្សេងៗ ឬការផ្លាស់ប្តូរបញ្ញត្តិ និងលក្ខខណ្ឌ**

២៤.១ ធនាគារឯកទេស អ៊ីអន អាចពីពេលមួយទៅពេលមួយ ដោយបានជូន ដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់កាតយ៉ាងហោចណាស់សាមសិប (៣០)ថ្ងៃប្រតិទិនជាមុន ធ្វើការកែប្រែ កែសម្រួល ឬផ្លាស់ប្តូរបញ្ញត្តិ និង លក្ខខណ្ឌដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹមការកាត់បន្ថយនៃកម្រិត ឥណទានលក្ខខណ្ឌនៃការទូទាត់ អត្រា និង/ឬវិធីសាស្ត្រនៃការគណនា សោហ៊ុយប្រចាំឆ្នាំ សោហ៊ុយដោះស្រាយ សោហ៊ុយបន្ថែម ការប្រាក់និងការពិន័យសម្រាប់ ការទូទាត់យឺតយ៉ាវ។ ការកែសម្រួល ការកែប្រែ ឬការផ្លាស់ប្តូរនឹង ត្រូវបាន អនុវត្តនៅលើកាលបរិច្ឆេទ ដែលកំណត់ដោយធនាគារឯកទេស អ៊ីអន និង ត្រូវអនុវត្តចំពោះគ្រប់សមតុល្យបំណុលទាំងអស់នៅក្នុងគណនី កាតឥណទាន ហើយការជូនដំណឹងអំពីការបន្ថែម ឬកែប្រែត្រូវមាន អានុភាពដោយៈ

ក) ការដាក់បង្ហាញសេចក្តីជូនដំណឹងនៅក្នុងបរិវេណនៃ ធនាគារ

ឯកទេស អ៊ីអន ឬ ការិយាល័យសាខារបស់ខ្លួន ឬដោយការផ្ញើសេចក្តីជូនដំណឹងខាងលើទៅម្ចាស់កាត ឬ

ខ) ការផ្ញើសេចក្តីជូនដំណឹងតាមរយៈការផ្ញើសារ ឬសារអេឡិចត្រូនិច ឬបង្ហាញសេចក្តីជូនដំណឹងនេះនៅលើគេហទំព័ររបស់ធនាគារឯកទេស អ៊ីអន។

២៤.២ ការរក្សាទុក ឬការប្រើប្រាស់កាតបន្ទាប់ពីកាលបរិច្ឆេទ ដែលការកែប្រែ កែសម្រួល ឬការផ្លាស់ប្តូរនៃបញ្ញត្តិ និងលក្ខខណ្ឌអនុលោមតាមប្រការ ២៤.១ មានអានុភាព ត្រូវបានចាត់ទុកថាជាការទទួលយកនូវការកែប្រែ កែសម្រួល ឬការផ្លាស់ប្តូទាំងនោះដោយគ្មានរក្សាសិទ្ធិណាមួយទុកដោយម្ចាស់កាត។

២៤.៣ ប្រសិនបើម្ចាស់កាតមិនទទួលយកការកែប្រែ កែសម្រួល ឬការផ្លាស់ប្តូរទាំងនោះ ម្ចាស់កាតត្រូវបញ្ឈប់ការប្រើប្រាស់កាតដោយជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ ធនាគារឯកទេស អ៊ីអន យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ហើយប្រគល់កាតនោះឱ្យទៅ ធនាគារឯកទេស អ៊ីអន វិញដោយកាត់ទទឹងលើម៉ាញ៉េទិក និងកាត់ឈីបមុនពេលកាលបរិច្ឆេទនៃការកែប្រែ ការកែសម្រួល ឬការផ្លាស់ប្តូរមានអានុភាពបានមកដល់ ហើយការប្រើប្រាស់កាតត្រូវចាត់ទុកថាបានបញ្ចប់នៅពេលដែលធនាគារឯកទេស អ៊ីអន ទទួលបានកាត ដែលត្រូវបានកាត់ទទឹងលើម៉ាញ៉េទិក និងកាត់ឈីប ហើយបញ្ញត្តិទាក់ទងនឹងការបញ្ឈប់ការប្រើប្រាស់កាតនៃប្រការ ២៣ ត្រូវយកមកអនុវត្ត។

**ប្រការ ២៥ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការដកសម្បទាណាមួយ ឬការបញ្ឈប់ការប្រើប្រាស់កាត**

ធនាគារឯកទេស អ៊ីអន មានសិទ្ធិតាមឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការដកចេញទាំងអស់ ឬផ្នែកសម្បទាណាមួយ នៅពេលណាមួយ ដោយជូនដំណឹងដល់ម្ចាស់កាត និងក្នុងកាលៈទេសៈណាមួយសមរម្យ ដើម្បីបញ្ឈប់ការប្រើប្រាស់កាត បើទោះបីជាធនាគារឯកទេស អ៊ីអន អាចធ្លាប់បានបោះបង់សិទ្ធិរបស់ខ្លួនពីមុនមកក៏ដោយ។ ក្នុងករណីម្ចាស់កាត  អសកម្មប្រតិបត្តិការកាតក្នុងរយៈពេលលើសពី១២ខែឡើងទៅ អ៊ីអនកាតរបស់ម្ចាស់កាត នឹងត្រូវបានបិទដោយស្វ័យប្រវត្តិដោយធនាគារឯកទេស អ៊ីអន។ ក្នុងករណីដែលម្ចាស់កាតនៅមានចំនួនទឹកប្រាក់ជំពាក់ធនាគារដែលរួមបញ្ចូលទាំង ការប្រាក់ ឬ កម្រៃសេវាផ្សេងៗ ម្ចាស់កាតត្រូវមានកាតព្វកិច្ចទូទាត់សងនូវបំណុលដែលនៅមានទាំងអស់មុនពេលធ្វើការបិទកាត។

**ប្រការ ២៦ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការដកយកមកវិញនូវកម្រិតឥណទានឬបដិសេធមិនឱ្យប្រើប្រាស់កាត**

២៦.១ ធនាគារឯកទេស អ៊ីអន មានសិទ្ធិនៅគ្រប់ពេលទាំងអស់ តាមឆន្ទានុសិទ្ធិរបស់ខ្លួន និងត្រូវជូនដំណឹងទៅម្ចាស់កាត ឬដោយមានមូលហេតុណាមួយ ដើម្បីដាក់កម្រិត ឬកំណត់ឥណទានរបស់ម្ចាស់កាត ឬបដិសេធ និង

ដកទុកឥណទាន។

២៦.២ ធនាគារឯកទេស អ៊ីអន មិនទទួលខុសត្រូវរាល់ការបាត់ ការរងគ្រោះ ឬការខាតបង់ទាំងឡាយណា ដែលកើតឡើងរួមមាន ផលវិបាក និងការបាត់បង់ផ្នែកសេដ្ឋកិច្ចរបស់ម្ចាស់កាត ជាលទ្ធផលនៃការបដិសេធប្រតិបត្តិការដោយធនាគារឯកទេស អ៊ីអន ដោយមូលហេតុដើម្បីការពារសុវត្ថិភាព។ ធនាគារឯកទេស អ៊ីអន ក៏មិនទទួលខុសត្រូវផងដែរចំពោះបញ្ហាដែលបណ្តាលមកពី ឬកើតឡើងដោយសារកំហុសរបស់ម៉ាស៊ីន ឬដំណើរការខុសប្រក្រតីនៃម៉ាស៊ីន ATM ឬរបស់បណ្តាញម៉ាស៊ី ATM ម៉ាកអន្តរជាតិ ATM ឬកំហុសបច្ចេកទេស ឬដោយកាលៈទេសៈ ណាមួយហួសពីការគ្រប់គ្រងរបស់ធនាគារឯកទេស អ៊ីអន ឬដោយការធ្វើកូដកម្ម ឬវិវាទការងារផ្សេងទៀត។

**ប្រការ ២៧ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការពិនិត្យឥណទានដែលមាន**

ធនាគារឯកទេស អ៊ីអន មានសិទ្ធិផ្តាច់មុខក្នុងការត្រួតពិនិត្យជាមួយការិយាល័យឥណទាន ឬបញ្ជីស្រដៀងគ្នាក្នុងគោលបំណងត្រួតពិនិត្យឥណទានរបស់ម្ចាស់កាតគ្រប់ពេល និងនៅពេលធនាគារឯកទេស អ៊ីអន សន្មតថាជាលក្ខខណ្ឌសមស្រប។ ម្ចាស់កាតពីពេលមួយទៅពេលមួយ តាមរយៈការស្នើសុំរបស់ធនាគារឯកទេស អ៊ីអន នឹងធ្វើសកម្មភាព ឬធ្វើឯកសារណាមួយដែលធនាគារឯកទេស អ៊ីអន តម្រូវដើម្បីបំពេញអានុភាពរបស់ប្រការនេះ។

**ប្រការ ២៨ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការបង្ហាញព័ត៌មាន**

២៨.១ ម្ចាស់កាតយល់ព្រមផ្តល់ព័ត៌មានអាសយដ្ឋានចុងក្រោយរបស់ម្ចាស់កាតទៅធនាគារណាមួយ ឬម៉ាកកាតឥណទានអន្តរជាតិ ឬសន្តតិជនរបស់ក្រុមហ៊ុនទាំងនោះ និងព័ត៌មានស្តីពីលេខកាតថ្មី លេខធ្វើជាថ្មី ឬលុបកាតចាស់ទៅឱ្យពាណិជ្ជករ ឬបុគ្គលដែលមានផលប្រយោជន៍។

២៨.២ ធនាគារឯកទេស អ៊ីអន ត្រូវមានសិទ្ធិបង្ហាញព័ត៌មាន ដោយម្ចាស់កាតព្រមបង្ហាញព័ត៌មានទៅឱ្យ ធនាគារឯកទេស អ៊ីអន នូវរាល់ព័ត៌មានទាក់ទិនទៅនឹងម្ចាស់កាត និង/ឬគណនីកាតឥណទាន ដែលវិសាលភាពនេះតាមឆន្ទានុសិទ្ធិផ្តាច់មុខ ឬឯកតោភាគីរបស់ខ្លួន ធនាគារឯកទេស អ៊ីអន គិតថាសមស្រប ទៅឱ្យការិយាល័យឥណទានណាមួយ ឬបញ្ជីស្រដៀងគ្នា រាប់បញ្ចូលប៉ុន្តែមិនកំណត់តាមប្រព័ន្ធព័ត៌មានកណ្តាលស្តីពីឥណទាន ដែលស្របតាមធនាគារជាតិនៃកម្ពុជា ការិយាល័យឥណទាននៃកម្ពុជា អង្គភាពព័ត៌មានឥណទាន និង/ឬ អាជ្ញាធរដទៃទៀត ឬអង្គភាពដែលបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា អាជ្ញាធរផ្សេងៗ ដែលមានយុត្តាធិការលើ ធនាគារឯកទេស អ៊ីអន សាខារបស់ធនាគារឯកទេស អ៊ីអន សាជីវកម្មដែលពាក់ព័ន្ធ ដៃគូពាណិជ្ជកម្ម បុត្រសម្ព័ន្ធ ក្រុមហ៊ុនពាក់ព័ន្ធនឹងអាជីវកម្ម អនុប្បទានិក អនុប្បទានិកតាមការស្នើសុំ ភ្នាក់ងារនិង/ឬ ភាគីដទៃទៀតដែលភ្ជាប់ដោយធនាគារឯកទេសអ៊ីអនធ្វើ ឬជួយធនាគារ

ឯកទេស អ៊ីអន អនុវត្តកាតព្វកិច្ច ឬធ្វើឱ្យមានសុពលភាពទៅលើសិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ដូចដែលមានចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ និង/ឬភាគីណាមួយដែល ធនាគារឯកទេស អ៊ីអន តាមការសម្រេចចិត្តឯកតោភាគីគិតថាត្រឹមត្រូវ។

២៨.៣ រាល់ព័ត៌មានដែលអនុញ្ញាតដោយ ធនាគារឯកទេស អ៊ីអន ដូចមានចែងក្នុងប្រការនេះមិនត្រូវនាំឱ្យមានការទទួលខុសត្រូវ របស់ធនាគារឯកទេស អ៊ីអន ទៅលើម្ចាស់កាតក្នុងករណីមានបណ្តឹង ការបាត់បង់ ការខូចខាត (រួមទាំងការខូចខាត ឬបាត់បង់អត្ថប្រយោជន៍ ឬសន្សំដោយផ្ទាល់ ឬដោយប្រយោល) ឬការទទួលខុសត្រូវដែលកើតឡើង ទោះបីជាមានកិច្ចសន្យា ឬការធ្វេសប្រហែស ឬបញ្ហាណាមួយដែលកើតឡើងពាក់ព័ន្ធនឹងករណីដូចខាងក្រោម៖

ក) ការចេញ ឬផ្តល់ព័ត៌មានដោយធនាគារឯកទេស អ៊ីអន និង/ឬ

ខ) ព័ត៌មានត្រូវបានកែតម្រូវ ភ័ន្តច្រឡំ ឬខុស និង/ឬ

គ) ផ្អែកលើព័ត៌មានទោះបីកើតឡើងដោយ ធនាគារឯកទេស អ៊ីអន ឬការលុបចោល ការអាក់ខាកមិនបានថ្លែង ការធ្វេសប្រហែស ឬកំហុសរបស់តតីយជនណាមួយ ឬដោយបញ្ហាបច្ចេកទេសផ្នែកhardware ឬ software នៃប្រភេទណាមួយដូចជាការរំខានមានបញ្ហា ការលុបចោលមេរោគ ការពន្យាពេលធ្វើបច្ចុប្បន្នភាព ឬជូនដំណឹងរាល់ការផ្លាស់ប្តូរណាមួយនៃព័ត៌មាន ឬលក្ខខណ្ឌផ្សេងៗដទៃទៀត។

២៨.៤ ធនាគារឯកទេសអ៊ីអន នឹងមិនបង្ហាញព័ត៌មានឥណទានរបស់ម្ចាស់កាតដល់ភាគីទីបីឡើយ។ ដូចគ្នានេះផងដែរ ធនាគារឯកទេសអ៊ីអន នឹងមិនប្រើប្រាស់ព័ត៌មានដែលទទួលបានពីប្រព័ន្ធរបាយការណ៍ឥណទាន ដើម្បីផ្តល់សេវាកម្មដល់ភាគីទីបី ឬដើម្បីធ្វើយុទ្ធនាការទីផ្សារ ក្រៅពីអតិថិជនដែលមានស្រាប់របស់ពួកគេឡើយ។

**ប្រការ ២៩ សិទ្ធិរបស់ធនាគារឯកទេស អ៊ីអន ក្នុងការតែងតាំងភ្នាក់ងារ**

ធនាគារឯកទេស អ៊ីអន ត្រូវមានសិទ្ធិដោយឯកតោភាគីក្នុងការតែងតាំងជម្រើសភ្នាក់ងារ (តទៅហៅថា ភ្នាក់ងារ) ដើម្បីប្រមូលរាល់ប្រាក់ដែលនៅជំពាក់ទាំងអស់ និងមួយចំនួនរបស់ធនាគារឯកទេស អ៊ីអន ពីម្ចាស់កាត ដោយស្ថិតនៅក្រោមបញ្ញត្តិ និងលក្ខខណ្ឌនេះដោយជូនព័ត៌មានជាមុនយ៉ាងតិចប្រាំពីរ (៧)ថ្ងៃនៃប្រតិទិន ហើយធនាគារឯកទេស អ៊ីអន ត្រូវមានសិទ្ធិជាឯកតោភាគីដើម្បីផ្តល់ព័ត៌មានទៅភ្នាក់ងារ (ដោយគ្មានការជូនដំណឹងទៅម្ចាស់កាត ឬ ផ្តល់ហេតុផលសមរម្យ) គណនីកាតឥណទាន និងព័ត៌មានដែលពាក់ព័ន្ធផ្សេងៗ គណនីកាតឥណទាន សម្របសម្រួលការប្រមូលនៃប្រាក់ដែលនៅជំពាក់ទាំងអស់ និងខ្ចីពីធនាគារឯកទេស អ៊ីអន ដោយម្ចាស់កាត។

**ប្រការ ៣០ ភស្តុតាងពិតប្រាកដ**

៣០.១ រាល់ការចុះឈ្មោះ ឬការទទួលស្គាល់ជាលាយលក្ខណ៍អក្សរដោយម្ចាស់កាត ឬបុគ្គលដែលផ្តល់សិទ្ធិដោយម្ចាស់កាតនៃទឹកប្រាក់ដែលនៅជំពាក់នៃម្ចាស់កាតទៅ ធនាគារឯកទេស អ៊ីអន និងសាលដីកាណាមួយ ដែលរកឃើញដោយធនាគារឯកទេស អ៊ីអន លើម្ចាស់កាតពាក់ព័ន្ធនឹងបំណុលទាំងនោះត្រូវជាប់កាតព្វកិច្ច និងសម្រេចដោយតុលាការស្របច្បាប់ទាំងនៅកម្ពុជា និងទីកន្លែងផ្សេង។

៣០.២ ម្ចាស់កាតយល់ព្រមយ៉ាងដាច់លាត់ និងដោយគ្មានការកែប្រែថា លិខិតបញ្ជាក់ពីបំណុល ដែលចេញដោយមន្រ្តីនៃធនាគារឯកទេស អ៊ីអន គឺជាភស្តុតាងបញ្ជាក់ និងចងកាតព្វកិច្ច នូវចំនួនទឹកប្រាក់ដែលបានជំពាក់ និង ដល់កំណត់សងជូនចំពោះ ធនាគារឯកទេស អ៊ីអន ដែលមានក្រោមគណនីកាតឥណទាន និងជាភស្តុតាងបញ្ជាក់ ដើម្បីប្រឆាំងនឹងម្ចាស់កាតនូវរាល់នីតិវិធីផ្លូវច្បាប់។

**ប្រការ ៣១ វិវាទ**

៣១.១ រាល់វិវាទដែលកើតឡើងពីរបាយការណ៍របស់ម្ចាស់កាត ត្រូវធ្វើឡើង ឬជូនដំណឹងមក ធនាគារឯកទេស អ៊ីអន ក្នុងរយៈពេលដប់បួន (១៤)ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃរបាយការណ៍។ ប្រសិនបើមិនដូច្នោះទេ ត្រូវសន្មតជារួមថាបានទទួលយកនូវរាល់ទឹកប្រាក់ដែលបានកំណត់ក្នុងរបាយការណ៍នោះ។

៣១.២ ក្នុងករណីម្ចាស់កាតមានវិវាទទាក់ទងនឹងប្រតិបត្តិការដូចដែលមានចែងក្នុងប្រការ៣១.១ នៃបញ្ញត្តិ និងលក្ខខណ្ឌនេះ ធនាគារឯកទេស អ៊ីអន អាចមានសិទ្ធិជាឯកតោភាគីកំណត់ពីភាពសមរម្យនៃការបើកការស៊ើបអង្កេត ដោយយោងតាមវិវាទនៃប្រតិបត្តិការដូចដែលមានចែងខាងក្រោម ហើយត្រូវយកមកអនុវត្តៈ

- ក) ប្រសិនបើការស៊ើបអង្កេតរបស់ធនាគារឯកទេស អ៊ីអន ត្រូវបានរកឃើញ ឬបញ្ជាក់ថាម្ចាស់កាតត្រូវទទួលខុសត្រូវនូវប្រតិបត្តិការដែលមានវិវាទធនាគារឯកទេស អ៊ីអន ត្រូវមានសិទ្ធិដូចករណីខាងក្រោមៈ
  - ១) ទាមទារថ្លៃសេវានៃការស៊ើបអង្កេតប្រាំ (៥)ដុល្លារអាមេរិក ឬទឹកប្រាក់ណាមួយដែលធនាគារឯកទេស អ៊ីអន គិតថាសមស្របតាមឆន្ទានុសិទ្ធិរបស់ខ្លួន។
  - ២) ការប្រាក់ចាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការដែលមានវិវាទ ការបញ្ចប់ការស៊ើបអង្កេត ដោយធនាគារឯកទេស អ៊ីអន។
- ខ) គ្មានការប្រាក់ និង/ឬគិតថ្លៃសេវាស៊ើបអង្កេតទេ ក្នុងករណីដែលការស៊ើបអង្កេតរកឃើញថាម្ចាស់កាតមិនមានកំហុស។

៣១.៣ ការស្វែងរករបស់ ធនាគារឯកទេស អ៊ីអន ពាក់ព័ន្ធនឹងគណនីកាតឥណទាន

ត្រូវបានសន្មតថាចូលជាស្ថាពរ និងចងភ្ជាប់កាតព្វកិច្ចរបស់ម្ចាស់កាត លុះត្រាតែមានភស្តុតាងផ្សេងមកបញ្ជាក់។

**ប្រការ ៣២ ការប្រឆាំងនឹងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងការត្រួតពិនិត្យលើការដាក់ទណ្ឌកម្មផ្សេង។**

៣២.១ ម្ចាស់កាតយល់ព្រមថាធនាគារឯកទេស អ៊ីអន អាចពន្យារ បិទ ឬបដិសេធ ដំណើរការនៃប្រតិបត្តិការណាមួយ ដោយរួចផុតពីការទទួលខុសត្រូវផ្សេងៗ ប្រសិនបើធនាគារឯកទេសអ៊ីអនសង្ស័យថា៖

ក) ប្រតិបត្តិការនោះអាចបំពានច្បាប់ ឬបទបញ្ញត្តិណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រទេសដទៃទៀត

ខ) ប្រតិបត្តិការពាក់ព័ន្ធនឹងបុគ្គលណាមួយ (រូបវន្តបុគ្គល នីតិបុគ្គល ឬរាជរដ្ឋាភិបាល) ដែលប្រតិបត្តិការនៃបុគ្គលនោះ ឬប្រតិបត្តិការនោះពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងបុគ្គលដទៃទៀត ដែលប្រតិបត្តិការរបស់បុគ្គលនោះស្ថិតនៅក្រោមទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្មដែលកំណត់ដោយសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ឬប្រទេសដទៃទៀត ឬ

គ) ប្រតិបត្តិការអាចពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងដំណើរការ ឬតម្រូវតាមគោលបំណងនៃការធ្វើប្រតិបត្តិការដែលខុសទៅនឹងច្បាប់នៃប្រទេសកម្ពុជា ឬប្រទេសដទៃទៀត។

៣២.២ ម្ចាស់កាតត្រូវផ្តល់ព័ត៌មានទាំងអស់ទៅធនាគារឯកទេស អ៊ីអន ដែលធនាគារឯកទេស អ៊ីអន មានហេតុផលសមរម្យក្នុងការតម្រូវឱ្យផ្តល់ព័ត៌មានទាំងនោះ ដើម្បីគ្រប់គ្រងលើហានិភ័យនៃការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្មរបស់ម្ចាស់កាត ឬដើម្បីអនុវត្តតាមការតម្រូវរបស់ច្បាប់ ឬបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ឬប្រទេសដ៏ទៃទៀត។ ដោយអនុលោមតាមបទបញ្ជាជាធរមាន សំណើសុំ ឬតម្រូវការ (ទោះបីជាមាន ឬគ្មានអានុភាពចាប់បង្ខំដោយច្បាប់) ពីអាជ្ញាធររាជរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចដ៏ទៃទៀត។

៣២.៣ ម្ចាស់កាតយល់ព្រមថា ធនាគារឯកទេស អ៊ីអន អាចបង្ហាញព័ត៌មានដែលពាក់ព័ន្ធនឹងម្ចាស់កាតក្នុងករណី៖

ក) ការអនុវត្តច្បាប់អាជ្ញាធរត្រួតពិនិត្យ ឬតុលាការដែលតម្រូវដោយច្បាប់ ឬបទបញ្ញត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬទីកន្លែងណាមួយផ្សេងទៀត និង

ខ) រាល់ទំនាក់ទំនងណាមួយ ដែលធនាគារឯកទេសអ៊ីអន ប្រើប្រាស់សម្រាប់ការទូទាត់ប្រាក់ក្នុងគោលបំណងអនុលោមតាមច្បាប់ ឬបទបញ្ញត្តិទាំងនោះ។

គ) នៅពេលក្រុមហ៊ុន ASF Corporation Co., Ltd. ASF Corporation Co., Ltd. ឬ ក្រុមហ៊ុនពាក់ព័ន្ធ ត្រូវតម្រូវឱ្យ

បង្ហាញព័ត៌មានដោយស្របតាមបទបញ្ជាណាមួយសំណើសុំ ឬតម្រូវការណាមួយ(ទោះបីជាមាន ឬគ្មានអានុភាពចាប់បង្ខំដោយច្បាប់) ពីរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចប្រទេសដទៃទៀត។ និង

យ) ក្រុមហ៊ុន ASF Corporation Co., Ltd. ឬក្រុមហ៊ុនពាក់ព័ន្ធ ឬអ្នកផ្តល់សេវាកម្មជូនទៅរបស់ក្រុមហ៊ុន ASF Corporation Co., Ltd. ឬផ្តល់សេវាឱ្យទៅក្រុមហ៊ុនពាក់ព័ន្ធដើម្បីបំពេញកិច្ចការរដ្ឋបាល ឬប្រតិបត្តិការផ្សេងៗ (រាប់បញ្ចូលទាំងការគ្រប់គ្រងហានិភ័យ ការប្រមូលបំណុលត្រឡប់មកវិញ ការទាមទារការបង្ហាញចំនួនណាមួយនៃដំណើរការទិន្នន័យ ការអភិវឌ្ឍន៍ និងការសាកល្បងនៃប្រព័ន្ធប្រតិបត្តិការ ការផ្តល់ពិន្ទុចំពោះឥណទាន ការបណ្តុះបណ្តាលបុគ្គលិក និងការស្រាវជ្រាវ ដើម្បីបំពេញតម្រូវការទីផ្សារ ឬម្ចាស់កាត។

៣២.៤ លើកលែងតែម្ចាស់កាតបានបង្ហាញព័ត៌មានថា ម្ចាស់កាតធ្វើសកម្មភាពក្នុងសមត្ថភាពជាអ្នកតំណាង ឬក្នុងនាមភាគីផ្សេងទៀត ម្ចាស់កាតត្រូវធានាថាម្ចាស់កាត និងអ្នកតំណាងស្របច្បាប់របស់ម្ចាស់កាតធ្វើសកម្មភាពក្នុងនាមជាម្ចាស់កាតក្នុងការចុះកិច្ចព្រមព្រៀងនេះ។

៣២.៥ ម្ចាស់កាតប្រកាសយល់ព្រម និងធានាចំពោះធនាគារឯកទេស អ៊ីអនថាដំណើរការ ឬប្រតិបត្តិការដែលធ្វើឡើងដោយធនាគារឯកទេស អ៊ីអនតាមរយៈការណែនាំរបស់ម្ចាស់កាតនឹងមិនបំពានច្បាប់ ឬបទបញ្ញត្តិណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬយុត្តាធិការដទៃទៀតឡើយ។

**ប្រការ ៣៣ ការកែតម្រូវប្រតិបត្តិការ**

ម្ចាស់កាតអាចមានសិទ្ធិកែតម្រូវប្រតិបត្តិការក្នុងករណី៖

៣៣.១ ម្ចាស់កាតមានទំនាស់ជាមួយពាណិជ្ជករណាម្នាក់។ ឧទាហរណ៍ ម្ចាស់កាតអាចមានសិទ្ធិទាមទារឱ្យកែតម្រូវនូវប្រតិបត្តិការជាមួយពាណិជ្ជករដែលមិនបានផ្តល់ទៅឱ្យម្ចាស់កាតនូវទំនិញ ឬសេវាកម្ម ដែលម្ចាស់កាតបានទូទាត់រួច។

៣៣.២ ម្ចាស់កាតត្រូវជូនដំណឹងទៅអ្នកចេញកាត ប្រសិនបើម្ចាស់កាតជឿជាក់ថាម្ចាស់កាតមានសិទ្ធិទទួលបានមកវិញនូវការកែតម្រូវប្រតិបត្តិការ។ ប្រសិនបើអ្នកចេញកាតយល់ព្រមបន្ទាប់ពីការស៊ើបអង្កេតឃើញថាម្ចាស់កាតមានសិទ្ធិទទួលបានមកវិញនូវប្រតិបត្តិការទឹកប្រាក់ដែលបានកាត់នោះនឹងត្រូវដាក់បញ្ចូលទៅគណនីរបស់ម្ចាស់កាតវិញ។

៣៣.៣ ម្ចាស់កាតត្រូវជូនដំណឹងទៅអ្នកចេញកាតភ្លាមៗពាក់ព័ន្ធនឹងប្រតិបត្តិការដែលមានវិវាទ។ វិធានប្រតិបត្តិការកាតឥណទានកំណត់អំពីពេលវេលាផុតសុពលភាព ដែលមិនតម្រូវឱ្យអ្នកចេញកាតទូទាត់ត្រលប់ទៅវិញនូវទឹកប្រាក់របស់ប្រតិបត្តិការ។ ជាទូទៅការកំណត់ពេលវេលាអប្បបរមា

ជាធរមានគឺ ៧៥ថ្ងៃបន្ទាប់ពីប្រតិបត្តិការដែលមានវិវាទនោះកើតឡើង ប៉ុន្តែពេលវេលាកំណត់ខ្លះអាចវែងជាងនោះ។ ប្រសិនបើម្ចាស់កាតមិនជូនដំណឹងមកអ្នកចេញកាតទាន់ពេលវេលាទេ អ្នកចេញកាតមិនមានលទ្ធភាពចុះស៊ើបអង្កេតទាមទាររបស់ម្ចាស់កាតឡើយ ក្នុងករណីនេះម្ចាស់កាតនឹងទទួលខុសត្រូវចំពោះប្រតិបត្តិការនោះ។

៣៣.៤ វាជាការទទួលខុសត្រូវរបស់ម្ចាស់កាតក្នុងការពិនិត្យមើលឱ្យច្បាស់ពីរបាយការណ៍គណនីរបស់ខ្លួន។ អ្នកចេញកាតមិនទទួលខុសត្រូវចំពោះការបាត់បង់ណាមួយរបស់ម្ចាស់កាត ប្រសិនបើម្ចាស់កាតមិនបានស្នើសុំទៅអ្នកចេញកាតឱ្យរក្សាទុកប្រតិបត្តិការណាមួយក្នុងអំឡុងពេលមានសុពលភាព។

**ប្រការ ៣៤ វិក្កយបត្របញ្ជាក់ពីការបង់ប្រាក់**

ឯកសារបញ្ជាក់ត្រូវបានចេញជូនម្ចាស់កាតនៅពេល ដែលមានការទូទាត់ពេញលេញដោយម្ចាស់កាតសម្រាប់ការទិញទំនិញ និងបានទូទាត់បំណុលដែលនៅជំពាក់ដោយម្ចាស់កាតទៅធនាគារឯកទេស អ៊ីអន។

**ប្រការ ៣៥ NO COOLING OFF**

មិនមានរយៈពេលទុកសម្រាប់ពិចារណាឡើងវិញនៃការទុករយៈពេលឱ្យម្ចាស់កាតពិចារណាឡើងវិញត្រូវបានយកមកអនុវត្ត។

**ប្រការ ៣៦ សោហ៊ុយ និងការចំណាយ**

ម្ចាស់កាតត្រូវទទួលខុសត្រូវក្នុងការបង់ទៅឱ្យធនាគារឯកទេស អ៊ីអន រាល់សេវាកម្មច្បាប់ទាំងអស់ (រួមទាំងសោហ៊ុយជាមូលដ្ឋានសម្រាប់ប្រឹក្សាយោបល់ជាមួយមេធាវី) ការគិតថ្លៃ និងការចំណាយដែលធនាគារឯកទេស អ៊ីអន អាចបង្ខំ ឬស្វែងរកការបង្ខំនៃប្រការណាមួយដូចដែលមានចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌ ឬដែលទទួលបានការបង់ប្រាក់ទាំងអស់ ឬមួយផ្នែកនៃទឹកប្រាក់ដែលខ្វះដោយម្ចាស់កាត។

**ប្រការ ៣៧ សំណង**

ម្ចាស់កាតត្រូវការពារធនាគារឯកទេស អ៊ីអន ពីគ្រោះមហន្តរាយទាំងឡាយឡាយ និងផ្តល់សំណងទៅឱ្យធនាគារឯកទេស អ៊ីអន ពាក់ព័ន្ធនឹងការបាត់បង់ ខូចខាត សោហ៊ុយ និងការចំណាយ(សេវាកម្មច្បាប់ ឬផ្សេងៗរួមបញ្ចូលទាំងសោហ៊ុយសម្រាប់ការប្រឹក្សាយោបល់ជាមួយមេធាវី) ដែលធនាគារឯកទេស អ៊ីអនអាចធ្វើឡើងដោយហេតុផលណាមួយដូចដែលមានចែងក្នុងប្រការនៃបញ្ញត្តិ និងលក្ខខណ្ឌ ឬបង្ខំឱ្យអនុវត្តសិទ្ធិរបស់ខ្លួនដូចដែលមានចែងក្នុងប្រការនៃបញ្ញត្តិ និងលក្ខខណ្ឌនេះ។

**ប្រការ ៣៨ ការបោះបង់សិទ្ធិ**

ការយល់ព្រមរបស់ធនាគារឯកទេស អ៊ីអន ទៅលើការបង់ប្រាក់យឺតទាំងស្រុង ឬផ្នែកណាមួយ ឬការបោះបង់សិទ្ធិណាមួយរបស់ខ្លួន ដើម្បីបំពេញតម្រូវការ ម្ចាស់

កាតមិនត្រូវបានយកមកអនុវត្ត ដើម្បីរារាំងសិទ្ធិក្នុងការប្រមូលនូវទឹកប្រាក់ដែលមិនទាន់បានសង ឬជាការបង្ហាញពីការយល់ព្រមក្នុងការកែប្រែនូវលក្ខខណ្ឌណាមួយដែលមានចែងក្នុងឯកសារនេះនោះទេ។

**ប្រការ ៣៩ សារៈសំខាន់នៃពេលវេលា**

៣៩.១ ពេលវេលាជាកត្តាសំខាន់ដូចដែលមានចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ។

៣៩.២ គ្មានការខកខានក្នុងការអនុវត្ត ឬគ្មានការពន្យាពេលក្នុងការអនុវត្តនៃផ្នែកណាមួយនៃសិទ្ធិអំណាច ឬអនុភាពរបស់ធនាគារឯកទេស អ៊ីអន ត្រូវបានចាត់ទុកថាជាការបោះបង់ចោល ហើយក៏គ្មានការអនុវត្ត សិទ្ធិ ឬអំណាច ឬអាទិភាពណាមួយត្រូវបានចាត់ទុកថានឹងមានការអនុវត្តសិទ្ធិដទៃផ្សេងទៀតនោះទេ។

៣៩.៣ សិទ្ធិ និងការទាមទារ ដែលចែងនៅក្នុងឯកសារនេះជាបន្ថែម ដែលមិនទាន់រាប់បញ្ចូលនូវសិទ្ធិ និងការទាមទារដទៃទៀតដែលមានចែងនៅក្នុងច្បាប់។

**ប្រការ ៤០ អនុប្បទាននៃសិទ្ធិ**

ធនាគារឯកទេស អ៊ីអន ត្រូវមានសិទ្ធិគ្រប់ពេលវេលាដោយគ្មានការយល់ព្រមជាមុនពីម្ចាស់កាតដើម្បីអនុប្បទានសិទ្ធិទាំងអស់ ឬផ្នែកណាមួយនៃសិទ្ធិ និងកាតព្វកិច្ចដូចដែលមានចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ។ ម្ចាស់កាតពីពេលមួយទៅពេលមួយតាមការស្នើសុំរបស់ធនាគារឯកទេស អ៊ីអន ធ្វើនូវសកម្មភាព ឬធ្វើលិខិតដើម្បីបំពេញឱ្យប្រការនេះមានប្រសិទ្ធិភាពអនុវត្ត។

**ប្រការ ៤១ ស្វ័យភាពនៃប្រការដែលមានចែង**

ប្រសិនបើប្រការណាមួយដូចដែលមានចែងក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះក្លាយជាអសុពលភាព ខុសច្បាប់ ឬគ្មានអានុភាពអនុវត្តដោយយោងតាមអានុភាពនៃច្បាប់ នីតិភាព សុពលភាពនៃប្រការ ដែលនៅសល់មិនត្រូវប៉ះពាល់ ឬដកហូតនោះទេ។

**ប្រការ ៤២ ច្បាប់គ្រប់គ្រង និងយុត្តាធិការ**

បញ្ញត្តិ និងលក្ខខណ្ឌនេះត្រូវសន្មតថាជាកិច្ចសន្យា ធ្វើឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយធ្វើឡើងសម្រាប់គោលបំណងគ្រប់គ្រង និងត្រួតពិនិត្យដោយច្បាប់កម្ពុជា ហើយភាគីតទៅនេះយល់ព្រមទទួលនូវយុត្តាធិការផ្សេងទៀតរបស់តុលាការកម្ពុជា ឬតុលាការដែលមានសមត្ថកិច្ចដទៃទៀត ដែលធនាគារឯកទេស អ៊ីអន ជ្រើសរើស។

**ប្រការ ៤៣ ការអនុវត្តនៃឯកសារបន្ថែម**

ម្ចាស់កាតត្រូវចុះហត្ថលេខាលើឯកសារបន្ថែម ដែលអាចផ្តល់ដោយធនាគារឯកទេសអ៊ីអន នៅពេលណាមួយ។

**ប្រការ ៤៤ សេចក្តីជូនដំណឹងស្តីពីការផ្លាស់ប្តូរ**

ម្ចាស់កាតត្រូវជូនដំណឹងភ្លាមៗទៅធនាគារឯកទេស អ៊ីអន ជាលាយលក្ខណ៍អក្សរចំពោះការផ្លាស់ប្តូរការងារ ឬអាជីវកម្ម អាសយដ្ឋាន (ការិយាល័យ ឬទីលំនៅ) ឬលេខទូរស័ព្ទ ឬប្រសិនបើម្ចាស់កាតមានចេតនាអវត្តមាននៅព្រះរាជាណាចក្រកម្ពុជាលើសពីសាមសិប (៣០)ថ្ងៃ។

**ប្រការ ៤៥ ការចាកចេញរបស់ម្ចាស់កាតពីកម្ពុជា**

៤៥.១ ក្នុងករណីម្ចាស់កាតត្រូវអវត្តមាននៅកម្ពុជាសម្រាប់រយៈពេលច្រើនជាងមួយ(១)ខែ ម្ចាស់កាតត្រូវជូនដំណឹងជាមុនអំពីការចាកចេញយ៉ាងតិចប្រាំពីរ (៧)ថ្ងៃ ទៅដើម្បីផ្ទៀតផ្ទាត់ទឹកប្រាក់ ដែលនៅសល់ក្រោមគណនីកាតឥណទាន។

៤៥.២ ក្នុងករណីម្ចាស់កាតត្រូវចេញពីកម្ពុជាដើម្បីស្នាក់នៅទីកន្លែងផ្សេង កាត និងកាតបន្ថែម (ប្រសិនបើមាន) ត្រូវយកមកឱ្យធនាគារឯកទេស អ៊ីអន វិញយ៉ាងតិចដប់បួន (១៤)ថ្ងៃ មុនការចាកចេញរបស់ម្ចាស់កាត ហើយការប្រើប្រាស់កាត និងកាតបន្ថែម (ប្រសិនបើមាន) ត្រូវសន្មតថាបញ្ចប់ ហើយប្រការដែលមានពាក់ព័ន្ធនឹងការបញ្ចប់ក្នុងប្រការ ២៣នៃបញ្ញត្តិ និង លក្ខខណ្ឌនេះត្រូវបានយកមកអនុវត្ត។

**ប្រការ ៤៦ លក្ខណៈខាងក្រៅ និងផលប្រយោជន៍នៃការធ្វើកាតម្តងទៀត**

ផ្សារភ្ជាប់ជាមួយការប្តេជ្ញារបស់ធនាគារឯកទេស អ៊ីអន ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនៃសេវាកម្មកាត និងអត្ថប្រយោជន៍ ធនាគារឯកទេស អ៊ីអន អាចពិនិត្យ និងកែប្រែលក្ខខណ្ឌ និងអត្ថប្រយោជន៍របស់កាតនៅពេលណាមួយ។

**ប្រការ ៤៧ វិវាទរវាងភាសាអង់គ្លេស និងភាសាដទៃទៀត**

ក្នុងករណីមានវិវាទ ឬភាពមិនស្របគ្នានៃភាសាអង់គ្លេសនៃបញ្ញត្តិ និងលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ និងភាសាដទៃទៀត ភាសាអង់គ្លេសត្រូវមានសុពលភាពអនុវត្ត។

**ប្រការ ៤៨ ការផ្សាយនៃបញ្ញត្តិ និងលក្ខខណ្ឌនៅលើគេហទំព័ររបស់ធនាគារឯកទេស អ៊ីអន**

ការចម្លងនៃបញ្ញត្តិ និងលក្ខខណ្ឌត្រូវបោះផ្សាយនៅគេហទំព័រ www.aeon.com.kh ដែលអាចកែប្រែនៅពេលណាមួយដោយជូនដំណឹងទៅម្ចាស់កាត។ ក្នុងករណីធនាគារឯកទេស អ៊ីអន កែប្រែ ឬផ្លាស់ប្តូរប្រការណាមួយនៃបញ្ញត្តិ និងលក្ខខណ្ឌនេះ វិសោធនកម្ម និងការកែប្រែថ្មីនឹងត្រូវចុះនៅក្នុងគេហទំព័រដូចដែលបានបង្ហាញខាងលើ។

**ប្រការ ៤៩ ករណីប្រធានសក្តិ**

ក្រៅពីប្រការដែលបានចែងក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ ម្ចាស់កាតយល់ព្រមថាមិនប្រគល់ការទទួលខុសត្រូវទៅ ធនាគារឯកទេស អ៊ីអន ក្នុងករណីដែលធនាគារឯកទេស អ៊ីអន មិនមានសមត្ថភាពទាំងអស់ ឬដោយផ្នែកនៃកាតព្វកិច្ច

របស់ខ្លួនដូចចែងក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ ដែលមានផលប៉ះពាល់ផ្ទាល់ ឬដោយប្រយោលដោយសារតែកំហុសផ្នែកមេកានិច ឬក៏ឧបករណ៍អេឡិចត្រូនិចប្រព័ន្ធកុំព្យូទ័រ បណ្តាញបញ្ជូន ការដាច់អគ្គិសនី វិវាទឧស្សាហកម្ម និងសកម្មភាពដទៃទៀត ដែលហួសពីការគ្រប់គ្រងរបស់ធនាគារឯកទេស អ៊ីអន ឬដោយសារកត្តាធម្មជាតិដែលជាប្រធានសក្តិ។ ក្នុងករណីធនាគារឯកទេស អ៊ីអន មិនមានលទ្ធភាពចេញនូវរបាយការណ៍វិក្កយបត្រដូចមានចែង ក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ សម្រាប់រយៈពេលណាមួយនៃការទទួលខុសត្រូវរបស់ម្ចាស់កាតលើហិរញ្ញវត្ថុ ឬសោហ៊ុយផ្សេងៗនឹងនៅតែបង្គរ ហើយគោលការណ៍គណនាទឹកប្រាក់ដែលត្រូវបង់ទៅធនាគារឯកទេស អ៊ីអន ឬកាលបរិច្ឆេទសម្រាប់ការបង់ការប្រាក់ និងប្រាក់ដើមអាចត្រូវបានជ្រើសរើសនៅថ្ងៃណាមួយនៃខែដូចដែលមានចែងនៅកាលបរិច្ឆេទនៃរបាយការណ៍ប្រចាំខែ។

**ប្រការ ៥០ ការទាក់ទងតាមរយៈទូរស័ព្ទ**

ម្ចាស់កាតយល់ព្រមថាធនាគារឯកទេស អ៊ីអន អាចរក្សាទុកនូវការសន្ទនារវាងពួកគេ ហើយរាល់ការកត់ត្រាទាំងឡាយត្រូវរក្សាជាទ្រព្យរបស់ធនាគារឯកទេស អ៊ីអន និងអាចប្រើប្រាស់ជាភស្តុតាងនៅពេលមានវិវាទណាមួយកើតឡើងលើគ្រប់រឿងក្តីណាមួយ ដែលពាក់ព័ន្ធនឹងបញ្ញត្តិ និងលក្ខខណ្ឌ និងម្ចាស់កាត។

ÆON
ធនាគារឯកទេស